ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

ត្រីមាសទី៤ ឆ្នាំ២០២៣

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក ស វ




ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

## គតិបណ្ឌិតសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

« អាណត្តិនេះ គេហៅថា អាណត្តិពង្រឹង
អាណត្តិពង្រឹងជាជាងពង្រីក ជាពិសេស ស្ថាប័នរដ្ឋ »

ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារក្រសួងពាណិជ្ជកម្ម
ឆ្នាំ២០២៣ និងទិសដៅការងារសម្រាប់ឆ្នាំ២០២៤
នៅទីស្តីការក្រសួងពាណិជ្ជកម្ម ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣

# មាតិកា


ទំព័រ

I- បទអត្ថាធិប្បាយ

- សង្គមវិជ្ជាជាអ្វី ? ១-៥

II- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣ ៦-១៥

III- នាទីសិក្សា-ស្រាវជ្រាវ

- ការសិក្សាស្រាវជ្រាវសាគរសាស្ត្រ និងធនធានជលផល នៅសមុទ្រកម្ពុជា ឆ្នាំ១៩៨៣-១៩៨៦ (តចប់) ១៦-២០

IV- នាទីវប្បធម៌

១- ជ្រុងមួយនៃភាសាខ្មែរ : ចម្ងល់យើងចំពោះពាក្យខ្មែរមាន « រ » (តចប់) ២១-២២

២- ស្វែងយល់ពី សីលធម៌សង្គមជាតិ ២៣-២៦

V- នាទីកំណាព្យ

១- កុំភ្លេចខ្លួន ! ២៧

២- រុក្ខជាតិស្រុកខ្មែរ (ពាក្យ៧) ២៧

VI- នាទីកំសាន្ត

- កម្រងនរកថា : ជាតិនេះស្មាលា ! ២៨-៣១

# សង្គមវិជ្ជាជាអ្វី?

១. និយមន័យនៃសង្គមវិជ្ជា (Définitions de la sociologie) :

-លោក អេមីល ឌៀរខេម (Emile Durkheim 1858-1917) សង្គមវិទូបារាំងបានសរសេរយ៉ាងដូចនេះថា : « La sociologie c´est l´étude des faits sosiaux » មានន័យថា « សង្គមវិជ្ជាជាការសិក្សាអំពីសង្គមការណ៍ »។ឯទ្រឹស្តីសង្គមរបស់លោកឌៀរខេម ថែងដូចតទៅ : « Tant qu´il y aura des riches et des pauvres de naissance, il ne sauraity avoir de contrat juste » មានន័យថា «ដរាបណានៅតែមានអ្នកមាននិងអ្នកក្រពីកំណើតមកតទៅទៀតគេពុំអាចធ្វើឱ្យមានកិច្ចសន្យាយុត្តិធម៌ក្នុងសង្គមទេ »។

-លោក អូគ្គុស កុង (Auguste Comte 1798-1857)[១] សង្គមវិទូបារាំងសតវត្សទី១៩ បានសរសេរថា ៖

ក. ដំបូងលោកបានប្រើពាក្យហៅសង្គមវិជ្ជាថា « រូបវិទ្យាអំពីសង្គម » (la physique sociale)។

ខ. បន្ទាប់មកលោកប្រើពាក្យហៅសង្គមវិជ្ជាថា « វិទ្យាសាស្ត្រអំពីបាតុភូតសង្គម » ( la science des phénomènes sociaux )។

គ. ទីបំផុតលោកកុងប្រើពាក្យសង្គមវិជ្ជានៅគ.ស.១៨៣៩ ដោយមានន័យថា : « សង្គមវិជ្ជាជាវិទ្យាសាស្ត្រវិជ្ជមានអំពីបាតុភូតសង្គម » (la sociologie est la science positive des phénomènes sociaux) បានសេចក្តីថា សង្គមវិជ្ជាសិក្សាអំពីបាតុភូតសង្គម ឆ្ពោះទៅរកអ្វីដែលចម្រើន អ្វីដែលមានផ្ទុយពីអ្វីដែលមាននៅក្នុងចិត្ត ផ្ទុយពីអ្វីដែលមាននៅតែក្នុងក្បួន។

(១) លោកកុងត្រូវគេចាត់ទុកជាបិតានៃសង្គមវិជ្ជា ព្រោះលោកជាអ្នកធ្វើឱ្យសង្គមវិជ្ជា មាន បែបផែនជាវិជ្ជាសិក្សាបែបវិទ្យាសាស្ត្រ។

១.១. វិទ្យាសាស្ត្រវិជ្ជមាន មានន័យដូចម្តេច?(Qu´est ce que la science positive?) វិទ្យាសាស្ត្រវិជ្ជមានអធិប្បាយអំពីអ្វីដែលវិនិច្ឆ័យបានដូចជាវិនិច្ឆ័យអំពីការរស់នៅ វិនិច្ឆ័យអំពីការពិត ហើយក៏ពន្យល់វែកញែកអំពីអ្វីដែលមាន (la science positive comporte des jugements d´existence ou de la réalité et tâche d´expliquer ce qui est. )

១.២.គំនិតវិជ្ជមាន មានន័យដូចម្តេច?(Qu´est ce que l´esprit positif?) គំនិតវិជ្ជមានជាគំនិតមួយពន្យល់អំពីអ្វីដែលមាន អ្វីដែលពិតផ្ទុយពីអ្វីដែលពុំពិតរវើរវាយ។

បុគ្គលដែលគេចាត់ទុកថាមានគំនិតវិជ្ជមាន គឺជាបុគ្គលដែលមានគំនិតដូចតទៅនេះ :

-គិតពីប្រយោជន៍គឺ មានប្រយោជន៍ទើបធ្វើ បើឥតប្រយោជន៍មិនធ្វើ

-មានលុយទើបចាយ បើអត់លុយមិនព្រមខ្ចីគេ

-មានលុយល្មមទិញផ្ទះ១ ឬឡាន១ទើបទិញ បើអត់លុយសុខចិត្តជួលផ្ទះគេ ឬសុខចិត្តដើរ

-មិនជឿលើអច្ឆរិយៈ

-វិនិច្ឆ័យតាមហេតុការណ៍ដែលកើតមានឡើង ដោយចាត់ទុកថាហេតុការណ៍ជាបម្រាប់ពិត (les données réelles) « បើមិនឃើញហេតុការណ៍មិនហ៊ានវិនិច្ឆ័យទេ ផ្ទុយពីបុគ្គលខ្លះ ដែលគ្រាន់តែឮគេនិយាយ មិនទាំងឃើញហេតុការណ៍ផង ក៏ហ៊ានវិនិច្ឆ័យទាំងងងឹតងងល់ » បុគ្គលជំពូកនេះមាន គំនិតវិជ្ជមាន(l´espritpositif)។បុគ្គលមានគំនិតអវិជ្ជមានជាបុគ្គលសាហាវណាស់ព្រោះបើបានកាន់តំណែងធំអាចយកមនុស្សទៅសម្លាប់ចោលផុយបំផុត ដោយគ្រាន់តែអាម៉ឺអាថោង ចាក់រុកឆ្កឹះផ្ញៀលបន្តិចបន្តួច ក៏

ចាត់ការវិនាសកម្មភ្លាម។បុគ្គលវិនិច្ឆ័យអ្វីៗដោយយកហេតុការណ៍ជាគោល គឺជាបុគ្គលប្រកបដោយគុណធម៌និងជាបុគ្គលប្រកបដោយគំនិតវិទ្យាសាស្ត្រ។ គំនិតវិជ្ជមានមានន័យម្យ៉ាងទៀតថាជាគំនិតមិនសើរើអតីតកាលមិនរកបុព្វហេតុដើមមិនគិតពីអ្វីដែលកន្លងផុតទៅហើយ យកហេតុការណ៍បច្ចុប្បន្នជា គោល ព្រោះមនុស្សអាចផ្លាស់ប្តូរចិត្តគំនិតរបស់ខ្លួនតាមកាលអាកាស។ ឧទាហរណ៍ : មនុស្សចិត្តល្អពុំ មែនចេះតែល្អរហូតទេ ឯមនុស្សចិត្តអាក្រក់ពុំមែនចេះតែអាក្រក់រហូតដែរ។ មនុស្សល្អអាចទៅជាអាក្រក់ ឯមនុស្សអាក្រក់អាចទៅជាល្អមុនពេលខ្លួនស្លាប់។ហេតុនេះគួរយកការណ៍បច្ចុប្បន្នសម្រាប់វិនិច្ឆ័យបុគ្គលពេលកំពុងប្រព្រឹត្ត។

១.៣. ការបង្រៀនវិជ្ជមាន មានន័យដូចម្តេច? (Qu´est ce qu´un enseignement positif?) ការបង្រៀនវិជ្ជមាន គឺជាការបង្រៀនមួយបែប ដោយចេះលើកយកភស្តុតាងផ្សេងៗមកបញ្ជាក់ ជាជំនួយដល់ការពន្យល់ ៖

-ការបង្រៀននៅថ្នាក់ទាបតម្រូវឱ្យមានសម្ភារៈសិក្សា (matériel didactique) ដូចជាការបង្រៀនអំពីរង្វាស់រង្វាល់ ត្រូវមានប្រដាប់ប្រដាសម្រាប់វាស់និងវាល់។

-ការបង្រៀននៅថ្នាក់ខ្ពស់ (ឧត្តមសិក្សា) តម្រូវឱ្យមានឯកសារត្រឹមត្រូវ(documents authentiques) សម្រាប់បញ្ជាក់ មិនចេះតែបង្រៀនតាមការនឹកឃើញ តាមយោបល់ផ្ទាល់របស់ខ្លួននោះទេ។ ឯកសារដែលត្រូវយកមកបញ្ជាក់គឺជាឯកសារត្រឹមត្រូវដែលត្រូវគេទទួលស្គាល់ទូទៅ ឬឯកសាររបស់អ្នកស្រាវជ្រាវពិតប្រាកដ។ ការលាក់បាំងឯកសារ ការបំភាន់ឯកសារដើម្បីឱ្យគេស្មានថាខ្លួនជាអ្នកបង្រៀនដ៏កំពូល គឺជាកំហុសមួយធ្ងន់ណាស់សម្រាប់អ្នកបង្រៀន គឺជាករណីដែលគួរលះបង់ដាច់ខាត។ ការបង្រៀនល្អមានជាការពន្យល់ ដោយអាងលើច្បាប់។

១.៤. លទ្ធផលវិជ្ជមាន២ មានន័យដូចម្តេច? (Qu´est ce qu´un résultat positif?) លទ្ធផលវិជ្ជមានគឺជាលទ្ធផលដែលមានរូបរាងពិតប្រាកដពុំមែននៅតែក្នុងក្រដាស ពុំមែននៅតែក្នុងច្បាប់ ពុំមែននៅតែក្នុងមាត់ដែលពោល ពុំមែនជាការបង្វែរដានទៅរកបញ្ហាដទៃទៀត... មានន័យថា ៖

-បើសុំឱ្យទំនិញចុះថោក ត្រូវតែបានឃើញទំនិញចុះថោកមែន

-បើសុំឱ្យបានឡើងប្រាក់ខែ ត្រូវតែប្រាក់ខែបានឡើងមែន

១.៥.សាសនាវិជ្ជមាន មានន័យដូចម្តេច?(Qu´est ce qu´une religion positive?) សាសនាវិជ្ជមានជាសាសនាដែលបដិសេធចោលអច្ឆរិយភាព ហើយពន្យល់តែទ្រឹស្តីណា ដែលមនុស្សអាចយល់បានអនុវត្តបាន សម្រាប់ស្វែងរកសេចក្តីសុខឱ្យមនុស្សផងគ្នា គឺជាសាសនាមនុស្សជាតិ (la religion de l´Humanité) ដូចនេះមិនត្រូវលើកតម្កើងបុគ្គលណាទេ ទោះបីបុគ្គលនោះជាអ្នកបង្កើតសាសនាក៏ដោយ៖

-ត្រូវប្រឆាំងនឹងជំនឿដែលជឿថា ព្រះអាទិទេពពូកែលើសអស់មនុស្សសត្វផងទាំងពួង ដូចជាសាសនាគ្រិស្ត និងសាសនាហិណ្ឌូ។

-ត្រូវឈ្វេងយល់ពីជំនឿដែលរំលំព្រះអាទិទេពចោលហើយតាំងខ្លួនជំនួសអាទិទេព ដូចជា ព្រះពុទ្ធសាសនា (ព្រះពុទ្ធអង្គកើតមកចេះដើរភ្លាម ចេះនិយាយ ចេះបញ្ចេញយោបល់ ចេះសម្តែងបាដិហារ្យគ្មានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ...)សាសនាមនុស្សជាតិបានត្រូវប្រទេសពីរបីចាប់អនុវត្តរួចហើយឯលទ្ធផលបានជោគជ័យជាងគេ គឺនៅប្រទេសប្រេស៊ីល (Brésil) សតវត្សទី២០នេះ។ រដ្ឋាភិបាលប្រេស៊ីលបានប្រកាសថាបើពិភពលោកទាំងមូលយល់ទ្រឹស្តីទាំងឡាយ ក្នុងសាសនាមនុស្សជាតិរបស់លោក អូគូស កុង ប្រហែលជាសង្គ្រាមនៅក្នុងពិភព

លោកឥតកើតមានទេ។ជំនឿលើសាសនានេះពុំតម្រូវឱ្យគោរពបុគ្គលអច្ឆរិយៈទេ លោក កុង ពុំដែលប្រកាសខ្លួនជាបុគ្គលប្រសើរជាងគេទេ។

រួមសេចក្តីមក វិទ្យាសាស្ត្រវិជ្ជមានក្តី គំនិតវិជ្ជមានក្តី ការបង្រៀនវិជ្ជមានក្តី លទ្ធផលវិជ្ជមានក្តី សាសនាវិជ្ជមានក្តី បានចងក្រងជាទ្រឹស្តីមួយមានឈ្មោះថា « ទ្រឹស្តីវិជ្ជមាននិយម » ( le Positivisme ) ដែលលោកអូគួសកុងបានអធិប្បាយយ៉ាងវែងនៅក្នុងទស្សនវិជ្ជារបស់លោក « ទស្សនវិជ្ជាវិជ្ជមាន » ( la Philosophie positive )។ លោកបានប្រកាសថាទស្សនវិជ្ជាវិជ្ជមានជាទស្សនវិជ្ជាប្រឆាំងនឹងការបំផ្លិចបំផ្លាញសព្វបែបយ៉ាង ហើយឱ្យតម្លៃលើការកសាង ការបង្កបង្កើត ការចាត់ចែងអង្គការ សម្រាប់សេចក្តីចម្រើនរបស់មនុស្សជាតិ។ សង្កេតតាម និយមន័យទាំងឡាយដូចបានអធិប្បាយរួចមកហើយយើងអាចឱ្យនិយមន័យសំយោគ លើពាក្យសង្គមវិជ្ជាដូចតទៅនេះ ៖

- «សង្គមវិជ្ជាជាវិជ្ជាសិក្សាអំពីបាតុភូតសង្គមទាំងឡាយ តាំងពីចិត្ត គំនិត មតិ យោបល់ ជំនឿ សាសនា មនោគមន៍ របបគ្រប់គ្រង ដែលជាវប្បធម៌ និងអរិយធម៌របស់ជនជាតិនីមួយៗ ដើម្បីឱ្យស្គាល់ព្រលឹងរបស់ជនជាតិនោះ »។ នៅសហរដ្ឋអាមេរិច គេច្រើនហៅសង្គមវិជ្ជាថា « Ecologie Sociale »។ តាមន័យនេះសង្គមវិជ្ជាជាវិជ្ជាមួយមានទំហំធំណាស់ លាតសន្ធឹងពាសពេញបញ្ហាសង្គមទាំងមូល ក្នុងពិភពលោក ប៉ុន្តែក្នុងការសិក្សាតទៅទៀត យើងយកតែសង្គមវិជ្ជាខ្មែរប៉ុណ្ណោះ មកធ្វើជាវត្ថុសិក្សា ចំណែកឯការសិក្សាសង្គមទូទៅជាកម្មវត្ថុនៃការសិក្សាថ្នាក់បណ្ឌិត។

- សង្គមវិជ្ជាប្លែកពីចិត្តវិទ្យាក្នុងករណីដែលចិត្តវិទ្យាសិក្សាអំពីបាតុភូតទាំងឡាយកើតមានក្នុងខ្លួនបុគ្គលដូចជាបាតុភូតតាមផ្លូវកាយចិត្តនិងគំនិតរបស់បុគ្គល ចំណែកឯសង្គមវិជ្ជាសិក្សាអំពីបាតុភូត ទាំងឡាយនៃសង្គម។

- សង្គមវិជ្ជាប្លែកពីអក្សរសិល្ប៍ក្នុងករណីដែលអក្សរសិល្ប៍លើកយកបញ្ហាបុគ្គលនីមួយៗមកបង្ហាញ ឆ្ពោះទៅរកបញ្ហាសង្គម តាមឯកសព្វវិធី ( méthode inductive ) ឯសង្គមវិជ្ជាលើកយក បញ្ហាសង្គមមកបង្ហាញ ឆ្ពោះទៅរកបញ្ហាបុគ្គល តាមសព្វឯកវិធី ( méthode déductive )។

- សង្គមវិជ្ជាប្លែកពីប្រវត្តិវិទ្យា ក្នុងករណីដែលប្រវត្តិវិទ្យាមានវត្ថុសិក្សា អំពីអតីតកាលរបស់មនុស្ស ដែលមិនវិលត្រឡប់មកវិញ ហើយគេអាចដឹងបានដោយសារឯកសារ ( l´histoire c´est l´étude du passé humain lequel ne se répète pas et n´est connu que par des documents ) ចំណែកឯសង្គមវិជ្ជាត្រូវពឹងពាក់លើប្រវត្តិវិទ្យា ប៉ុន្តែសង្គមវិជ្ជាមានករណីពន្យល់វែកញែកបំភ្លឺអតីតកាលដែលកន្លងផុតទៅ ដើម្បីប្រមើលមើលហេតុការណ៍ទៅអនាគត ក្រែងមានហេតុការណ៍ថ្មីអាចកើតឡើងវិញប្រហែលគ្នានឹងហេតុការណ៍ដែលកន្លងផុតមកហើយ។ ត្រង់ចំណុចនេះ អ្នកសិក្សាប្រវត្តិវិទ្យាខ្លះច្រើនច្រឡំប្រវត្តិវិទ្យានិងសង្គមវិជ្ជាដោយហេតុតែសង្គមវិជ្ជាមានទំនាក់ទំនងនឹងប្រវត្តិវិទ្យានៅពេលដែលគេលើកយកប្រវត្តិការណ៍ ( fait historique ) មកធ្វើជាវត្ថុសិក្សា។ ដោយហេតុថាមានមតិជាច្រើនពន្យល់ពាក្យសង្គមវិជ្ជាតាមនិយមន័យប្លែកៗគ្នាទើបសង្គមវិទូជាច្រើនខំបង្កើតលក្ខណៈវិនិច្ឆ័យ ដើម្បីសម្គាល់បាតុភូតសង្គមដែលគេនាំគ្នាហៅថា« សង្គមការណ៍ » ( fait social ) ព្រោះសង្គមការណ៍ជាធាតុសំខាន់ នៃការសិក្សាសង្គមវិជ្ជា ពោលគឺ សង្គមការណ៍ជាសារជាតិរបស់សង្គមវិជ្ជា ( C´est la substance de la sociolo gie ) ។

២. លក្ខណៈវិនិច្ឆ័យនៃសង្គមការណ៍ ( Critère des faits sociaux )

២.១.សង្គមការណ៍ពុំមែនជាប្រវត្តិការណ៍ទេព្រោះប្រវត្តិការណ៍គ្រាន់តែបង្ហាញកាលប្រវត្តិ ថ្ងៃនេះ ថ្ងៃនោះ មានរឿងបែបនេះបែបនោះ ដូចជាថ្ងៃ ១៨ មីនា ១៩៧០ជាថ្ងៃប្រវត្តិការណ៍ព្រោះជាថ្ងៃដែលមានកើតវិបត្តិសង្គម ប៉ុន្តែបើយើងដេញដោលសួររកប្រភពនៃចលាចលនេះ ៖

-កើតមកពីណា?

-អ្នកណាជាអ្នកបង្កើត?

-អ្នកបង្កើតវិបត្តិសង្គមនេះមានអតីតកាលដូចម្ដេច?

-ក្នុងបច្ចុប្បន្ននេះមានសកម្មភាពដូចម្ដេច?

-ទៅអនាគតនឹងក្លាយទៅជាយ៉ាងណា?

-វិបត្តសង្គមទើបតែពន្លកឡើង ឬមួយគេរៀបចំយូរមកហើយ ?

-តើគំនិតដែលបម្រុងបង្កើតវិបត្តិសង្គមមានរូបរាងឡើងពីសម័យកាលណាមក?

-តើខ្មែរយើងធ្វើខ្លួនឯង ឬបរទេសឱ្យធ្វើ?

-តើខ្មែរធ្លាប់ពឹងបរទេសឬទេពីអតីតកាល?

-តើខ្មែរឈ្លោះនឹងខ្មែរគ្នាឯង ឬខ្មែរឈ្លោះនឹងបរទេស?

-តាមប្រវត្តិពីអតីតកាលមក តើខ្មែរនិយមឈ្លោះជាមួយនិងគ្នាឯង ឬនិយមឈ្លោះជាមួយនិងបរទេស?

-តើគេចូលចិត្តឈ្លោះគ្នាពីរឿងអ្វី? រឿងជាតិ ឬរឿងផ្ទាល់ខ្លួន?រឿងរៀបចំសង្គមឬរឿងបុណ្យសក្តិ? ... ទាំងអស់នេះជាវត្ថុសិក្សារបស់សង្គមការណ៍ឯសង្គមការណ៍គឺជាសារជាតិ និងជាខ្លឹមនៃសង្គមវិជ្ជាដើម្បីដោះស្រាវជ្រាវរកព្រលឹងនៃជនជាតិនីមួយៗ។ ការសិក្សាស្រាវជ្រាវរកព្រលឹងនៃជនជាតិនីមួយៗនឹងមានលក្ខណៈច្បាស់លាស់បាន លុះណាតែអ្នកសរសេរមានគំនិតវិទ្យាសាស្ត្រព្រមទាំងស្មោះត្រង់នឹងកិច្ចការរបស់ខ្លួន (la probité d´un écrivain)។

២.២. សង្គមការណ៍ពុំមែនជាសរីរការណ៍ទេ ពីព្រោះសរីរការណ៍ជាហេតុការណ៍ កើតមានឡើងក្នុងសរីរៈរបស់បុគ្គលទូទៅពោលគឺសរីរៈរបស់មនុស្សពីធម្មជាតិមក។ ឧទាហរណ៍ : ខ្មែរសំបុរលឿង បារាំងសំបុរសខ្មែរបរិភោគបាយបារាំងបរិភោគនំប៉័ងស្រីខ្មែរចេះអៀនខ្មាស់ជាងប្រុស ... ទាំងអស់នេះសុទ្ធសឹងជាសរីរ-ការណ៍ហើយមិនត្រូវច្រឡំថាជាសង្គមការណ៍ទេពោលគឺ ពុំមែនជាព្រលឹងរបស់ជនជាតិខ្មែរនិមួយៗ ឡើយ។ បញ្ជាក់:លោកឈូកម៉ឺងម៉ៅអគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំចំណេះទូទៅ បានផ្សាយតាមវិទ្យុជាតិរៀងរាល់ថ្ងៃអាទិត្យថា ព្រលឹងខ្មែរឋិតនៅត្រង់ស្ត្រីខ្មែរចេះអៀន! នេះជាការភាន់ច្រឡំមួយ ព្រោះជាសរីរ-ការណ៍ (C´est plutôt un fait physi- ologique) ដែលកើតមានតាមធម្មជាតិនៅក្នុងចិត្តគំនិតរបស់ស្រីពោលគឺស្រីអៀនខ្មាស់ច្រើនជាងប្រុស ហើយជាធម្មជាតិរបស់ស្រីៗ មិនថាស្រីខ្មែរ ចិន ចាម សៀម បារាំង... (C´est la nature féminine)។

២.៣. សង្គមការណ៍ពុំមែនជាបុគ្គលការណ៍ទេពីព្រោះបុគ្គលការណ៍ (fait individuel) ជាហេតុការណ៍ដែលកើតឡើងក្នុងខ្លួនបុគ្គល ក្នុងឋានៈជាមនុស្សម្នាក់ ឯសង្គមការណ៍ត្រូវប៉ះពាល់លើមនុស្សភាគច្រើន។ ឧទាហរណ៍ :

-មនុស្សម្នាក់ចូលចិត្តមើលកុនមើលល្ខោន ពុំមានន័យថាខ្មែរទាំងអស់ចូលចិត្តមើលកុនមើលល្ខោនទេ បុគ្គលការណ៍

-បើខ្មែរទាំងអស់ចូលចិត្តមើលកុនមើលល្ខោន សង្គមការណ៍ កំណត់សម្គាល់ : « ខ្មែរជាពូជអ្នកចម្បាំង » ជាបុគ្គលការណ៍ ឬ ជាសង្គមការណ៍? តាមប្រវត្តិវិទ្យាខ្មែរ ខ្មែរពុំនិយមសង្គ្រាមទេ ខ្មែរនិយមតែសេចក្ដីសុខបើបែរជាចង់ច្បាំងវិញខ្មែរច្រើនតែច្បាំងចាញ់ ប៉ុន្តែបានឈ្នះម្ដងនៅសម័យព្រះបាទជ័យវរ្ម័នទី៧ និងទប់ទល់បានខ្លះ នៅសម័យព្រះបាទសុរិយោវង្សកម្ទេចសៀមនៅសៀមរាបរួចហើយក៏ចាញ់រហូត។ ខ្មែរចូលចិត្តកសាង ដូចជា សិល្បករ សិប្បករ ជាង និងអ្នកបច្ចេកទេសផ្សេងៗ ខ្មែរពុំចូលចិត្តនយោបាយទេ ហើយពុំចេះធ្វើនយោបាយផង បើបែរជាចង់ធ្វើនយោបាយវិញគឺគ្រាន់តែដើម្បីប្រមូលអំណាចប្រមូលបុណ្យសក្តិ ប្រមូលប្រពន្ធ ...។ កាលព្រឹត្តិការណ៍ថ្ងៃទី ៣០និង៣១កក្កដា១៩៧៣អាជ្ញាធរប្រដាប់អាវុធដើរចាប់ប្រជាពលរដ្ឋ ធ្វើទាហាននៅពាសពេញទីក្រុង

ភ្នំពេញ តើទីក្រុងមានទិដ្ឋភាពដូចម្តេច? ស្វាត់ជ្រងំ ប្រុសៗលែងហ៊ានចេញដើរ កម្មករស៊ីក្លូនិងកម្មករលីសែងឈប់មានសកម្មភាព រោងកុនគ្មានមនុស្សមើល គុគុយទាវមានពីរបីនាក់ ហើយហាងភាគច្រើនបិទទ្វារ តើនេះ បង្ហាញថាខ្មែរចូលចិត្តសង្គ្រាមឬទេ ? បើមានខ្មែរណាម្នាក់ចេះធ្វើនយោបាយ គឺជាខ្មែរពិសេស បុគ្គលការណ៍ ហេតុនេះពាក្យថា« ខ្មែរជាពូជអ្នកចម្បាំង » គឺជាបុគ្គលការណ៍ ពោលគឺជាគំនិតរបស់បុគ្គលខ្លះប៉ុណ្ណោះដែលនិយមសង្គ្រាមដើម្បីយកសង្គ្រាមធ្វើជាមធ្យោបាយបង្កើនទ្រព្យសម្បត្តិបុណ្យសក្តិនិងស្រី...។ តាមអត្ថបទអក្សរសិល្ប៍ខ្មែរវិញ ករណីរបស់ព្រះបាទរាមាក្នុងរឿងទុំទាវ ដែលបានលើកលែងទោសឱ្យទុំ នៅពេលទុំច្រៀងទាមទារយកនាងទាវមកវិញ តើអាចចាត់ទុកជាបុគ្គលការណ៍ ឬសង្គមការណ៍?

-បើស្តេចខ្មែរទាំងអស់មានទម្លាប់សន្តោសគូប្រជែងរបស់ខ្លួនក្នុងរឿងស្នេហា សង្គមការណ៍

-ប៉ុន្តែការសន្តោសរបស់ព្រះបាទរាមាក្នុងរឿងទុំទាវ ជាលក្ខណៈផ្ទាល់របស់ព្រះអង្គពុំមែន តំណាងស្តេចទូទៅទេ ព្រោះតួយ៉ាងដូចជា ព្រះឧទ័យ បានហៅទ័ពបរទេសឱ្យសម្លាប់ព្រះរាជសម្ភារ ( ពញាតូ) ជាក្មួយរបស់ឯងក្នុងរឿងដណ្តើមនាងបុប្ផារត្តី។ចំណែកព្រះបាទរាមាសន្តោសទុំ មកពីព្រះ អង្គ ដឹងថានាងទាវអស់មានសារៈសំខាន់ចំពោះព្រះអង្គទៀតហើយ ខ្លឹមស្នេហារបស់នាងត្រូវទុំប្រមូលយកអស់នៅសល់តែកាកស្នេហា បើទទួលយកស្នេហាក្រោយទុំ ហាក់ដូចជាអន់ថយពន់ពេកណាស់។ហេតុនេះការសន្តោសរបស់ព្រះបាទរាមា បុគ្គលការណ៍។

២.៤. សង្គមការណ៍ពុំមែនជាអន្តរបុគ្គលការណ៍( fait inter-individuel ) ពីព្រោះអន្តរបុគ្គលការណ៍សម្គាល់នូវហេតុការណ៍ ដែលកើតមានឡើងត្រឹមតែការស្និទ្ធស្នាលពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតឬពីគ្រួសារមួយទៅគ្រួសារមួយទៀត។ ដើម្បីឱ្យអន្តរបុគ្គលការណ៍ក្លាយទៅជាសង្គមការណ៍បាន លុះត្រាតែមានសន្ទុះប៉ះពាល់ដល់បញ្ហាសង្គមទាំងមូល។ ឧទាហរណ៍ : ករណីរបស់លោកហ្លួងរតនសម្បត្តិដែលជាមហាសេដ្ឋីក្នុងរឿងកុលាបប៉ៃលិន យល់ព្រមលើកកូនក្រមុំ យ៉ាងល្អស្អាតឱ្យទៅចៅចិត្រជាកម្មកររបស់ខ្លួន ពុំមែនជាករណីទូទៅរបស់មហាសេដ្ឋីនៅស្រុកខ្មែរទេគឺគ្រាន់តែជាការព្រមព្រៀងគ្នាពីគ្រួសារមួយទៅគ្រួសារមួយទៀតប៉ុណ្ណោះ ដូចនេះគឺជាអន្តរបុគ្គលការណ៍។

២.៥. លោក គ្គាព្រីយែល តាត ( Gabriel Tarde 1843 - 1904 ) សង្គមវិទូបារាំងបានបង្កើត លក្ខណៈវិនិច្ឆ័យនៃសង្គមការណ៍ ដោយពន្យល់ថាសង្គមការណ៍ជាហេតុការណ៍ទូទៅ កើតឡើងដោយបាតុភូតទាក់ទងទៅនឹងជំនឿ សាសនា ទំនៀមទម្លាប់ ការអប់រំ សេដ្ឋកិច្ច មនោគមន៍ របបគ្រប់គ្រងទាំងមូល បន្ថែមលើយោបល់ពីមុន ដោយអះអាងថា « អ្វីដែលចាត់ទុកជាសង្គមការណ៍ លុះត្រាតែមានការបង្ខិតបង្ខំចេញមុខពីសង្គម ឧបមាសង្គមបង្ខំឱ្យធ្វើអ្វីមួយ បើមិនធ្វើតាមនឹងត្រូវមានទោស ដូចជា ៖

-ទោសក្នុងផ្លូវជំនឿ ( sanctions mystiques )

-ទោសក្នុងផ្លូវច្បាប់ ( sanctions juridiques )

-ទោសក្នុងផ្លូវសីលធម៌ ( sanctions éthiques )

-ទោសដោយទទួលការតិះដៀលពីអ្នកដទៃ ហើយគ្មានសិទ្ធិឆ្លើយតប( sanctions satiriques )។

រួមសេចក្តីមក លក្ខណៈវិនិច្ឆ័យទាំងឡាយរបស់សង្គមការណ៍ ដូចបានអធិប្បាយរួចមកហើយ បានបង្ហាញឱ្យឃើញថា សង្គមការណ៍ប្រកបដោយគោលការណ៍សំខាន់ៗ ដូចតទៅ ៖

-មានលក្ខណៈទូទៅ

-ទៀងទាត់មិនប្រែប្រួល

-មានខ្លឹមរបស់ខ្លួន

-ក្នុងវប្បធម៌និងអរិយធម៌របស់ជនជាតិនិមួយៗ

-មានតម្លៃពីអតីតកាលឆ្លងទៅអនាគតកាល

-ជួនកាលមានទំនាក់ទំនងរវាងសរីរការណ៍ បុគ្គលការណ៍ អន្តរបុគ្គលការណ៍ ឆ្ពោះទៅរកសង្គមការណ៍ ... ទើបគេអាចចាត់ទុកថាសង្គមការណ៍ជាប្រភព នៃការស្រាវជ្រាវរកព្រលឹងជនជាតិនិមួយៗដូចជាការស្រាវជ្រាវរកព្រលឹងរបស់ខ្មែរជាដើម។

## II- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣*

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (**ក.ស.វ.**) បានធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់កម្ពុជាប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣ ដោយផ្អែកលើទិន្នន័យព័ត៌មានដែលទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមតិយោបល់ដែលជាធាតុចូលពីកិច្ចប្រជុំទូលាយរបស់**ក.ស.វ.** ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងកិច្ចប្រជុំចង្អៀតផ្សេងទៀត របស់ក.ស.វ. ដោយឈរលើគោលការណ៍បរិយាបន្ននៃសេចក្តីវិនិច្ឆ័យ ដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

### ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➡ នាត្រីមាសទី៣ ឆ្នាំ២០២៣ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង១,៤% ធៀបនឹងត្រីមាសមុន និងកើនឡើង៣,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង១.១- បម្រែបម្រួលថ្លៃធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន សម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ* | | *មុខទំនិញ* | |
|---|---|---|---|
| ម្ហូបអាហារ | +៣,៩% | បន្លែ | +៦,៥% |
| សម្លៀកបំពាក់និងស្បែកជើង | +៣,៨% | ផ្លែឈើ | +៥,៣% |
| ការកម្សាន្តនិងវប្បធម៌ | +៣,៧% | ត្រីស្រស់ | +៤,៨% |
| ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +៣,២% | សាច់ជ្រូក | +៣,១% |
| ទំនិញនិងសេវាកម្មផ្សេងៗ | +២,៩% | សាច់គោ | +២,៦% |
| ភោជនីយដ្ឋាន | +២,៧% | សាច់មាន់ | +១,៩% |
| គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ | +១,៦% | អង្ករ | +១,៦% |

ក្រាហ្វ ១.១- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំត្រីមាស និងបម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន




* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរនិងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឱ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឱ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។




តារាង១.២- អត្រាប្តូរប្រាក់

| *បរិយាយ* | *ត្រីមាសទី៣ ២០២៣* | *ត្រីមាសទី២ ២០២៣* | *ត្រីមាសទី៣ ២០២២* |
|---|---|---|---|
| **រ/ដុល្លារ** | ៤ ១២២រ/$ | ៤ ១៣០រ/$ | ៤ ១១៩រ/$ |
| **រ/បាត** | ១១២រ/បាត | ១១៦រ/បាត | ១០៨រ/បាត |
| **រ/ដុង** | ០,១៦៩រ/ដុង | ០,១៧៥រ/ដុង | ០,១៧៣រ/ដុង |
| **បាត/ដុល្លារ** | ៣៦,៥បាត/$ | ៣៥,៥បាត/$ | ៣៨,១បាត/$ |
| **ដុង/ដុល្លារ** | ២៤ ២៧៤ដុង/$ | ២៣ ៥៧៩ដុង/$ | ២៣ ៨២០ដុង/$ |
| **យ៉ន់/ដុល្លារ** | ៧,៣យ៉ន់/$ | ៧,៣យ៉ន់/$ | ៧,១យ៉ន់/$ |

## ២. ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

ក្រាហ្វ ២.១- ចំណូលថវិកាជាតិ ឆ្នាំ២០២១ ដល់ ឆ្នាំ២០២៣ (ប៊ីលានរៀល)



**២.១- ចំណូលថវិកាជាតិ** : អនុវត្តបាន៥ ៦២៩,៦ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ១ ៣៦៥,៧លានដុល្លារ (*មធ្យមប្រចាំខែ៩៦,១%នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន៥ ៣៤៩,៨ប៊ីលានរៀល គិតជាដុល្លារអាម៉េរិក ស្មើ ១ ២៩៧,៩លានដុល្លារ (*មធ្យមប្រចាំខែ៩៦,០% នៃផែនការ*) និងចំណូលមូលធនចំនួន២៧៩,៨ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ៦៧,៩លានដុល្លារ (*មធ្យមប្រចាំខែ៩២,៣% នៃផែនការ*) (តាមតួលេខរតនាគារជាតិ)។

➢បើធៀបនឹងត្រីមាសមុន ចំណូលថវិកាជាតិថយចុះ២៧,៧% និងថយចុះ៤,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។

➢ក្នុងចំណូលចរន្ត:

- ✓ ចំណូលសារពើពន្ធមានចំនួន៥ ៣៧៧,៤ប៊ីលានរៀលថយចុះ៤,៤% ធៀបនឹងត្រីមាសមុន និងថយចុះ១០,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន(តាមតួលេខអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ)។ ចំណែកតាមតួលេខរតនាគារជាតិ ចំណូលសារពើពន្ធមានចំនួន៤ ៧៤២,៥ប៊ីលានរៀលថយចុះ១៦,៦%ធៀបនឹងត្រីមាសមុន និងថយចុះ៨,៨%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- ✓ ចំណូលមិនមែនសារពើពន្ធ មានចំនួន៦០៧,២ប៊ីលានរៀលថយចុះ១៥,៧% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៣,៨%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន(តាមតួលេខរតនាគារជាតិ)។

**តារាង២.១- មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| ចំណូលសារពើពន្ធ បម្រែបម្រួល ធៀបនឹងត្រីមាស.. | | | ចំណូលមិនមែនសារពើពន្ធ បម្រែបម្រួល ធៀបនឹងត្រីមាស.. | | |
|---|---|---|---|---|---|
| | មុន | ដូចគ្នាឆ្នាំមុន | | មុន | ដូចគ្នាឆ្នាំមុន |
| ពន្ធនិងអាករគយ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | -០,៧% | -២៣,៧% | អាជ្ញាបណ្ណក្នុងស្រុក | +៣៨៦,៥% | +១៨៣,៨% |
| | | | កម្រៃការគ្រប់គ្រង និង ទិដ្ឋាការនាំចេញ | +៧,៤% | -៣០,៣% |
| | | | សម្បទានរ៉ែ | +២៣,១% | +៥៣,៨% |
| ចំណូលពន្ធដារ (អគ្គនាយកដ្ឋានពន្ធដារ) | -៧,១% | +៣,៨% | អាកាសចរណ៍ស៊ីវិល | -៤៧,២% | -១៥,៨% |
| | | | ផលទុននៃសកម្មភាពទេសចរណ៍ | -៣១,៩% | +៩៧,១% |

**២.២- ចំណាយថវិកាជាតិ** : អនុវត្តបាន៦ ៨១០,៣ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ១ ៦៥២,២លានដុល្លារ(*មធ្យមប្រចាំខែ៨២,៥%នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន៤ ៦៧២,៧ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ១ ១៣៣,៦លានដុល្លារ(*មធ្យមប្រចាំខែ៨៩,០%នៃផែនការ*) និងចំណាយមូលធនមានចំនួន២ ១៣៧,៦ប៊ីលានរៀល គិតជាដុល្លារអាម៉េរិក ស្មើ៥១៨,៦ លានដុល្លារ(តាមតួលេខ រតនាគារជាតិ)។ ចំណាយថវិកាជាតិកើនឡើង១២,៩% ធៀបនឹងត្រីមាសមុន និងកើនឡើង២៥,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង២,២% ធៀបនឹងត្រីមាសមុន និងកើនឡើង១២,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

ក្រាហ្វ២.២- ចំណាយថវិកាជាតិ ឆ្នាំ២០២១ ដល់ ឆ្នាំ២០២៣ (ប៊ីលានរៀល)




**២.៣- សមតុល្យថវិកាជាតិ** : ថវិកាជាតិនាត្រីមាសទី៣នេះ មានឱនភាពចំនួន១ ១៨០,៧ប៊ីលានរៀល គិតជាដុល្លារ អាម៉េរិកស្មើ២៨៦,៤លានដុល្លារ (តួលេខរតនាគារជាតិ)។

## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ $M_2$ មានចំនួន១៨៧ ២៣៧,៥ ប៊ីលានរៀលមានការកើនឡើង២,៦%ធៀបនឹងត្រីមាសមុន និង កើនឡើង១០,៥%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ **ការកើនឡើង** $M_2$ ក្នុងត្រីមាសនេះ ជារួមបណ្ដាលមកពីការកើនឡើងនៃប្រាក់បញ្ញើផ្សេងទៀត៣,៨%។

ក្រាហ្វ៣.១- សមាសធាតុរូបិយវត្ថុ




➢ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ ប្រាក់រៀលនៅក្នុង និងក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើរមានចំនួន១៦,៨% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,២% នៃរូបិយវត្ថុ$M_2$។

តារាង៣.១- សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០២២

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុង និងក្រៅស្ថាប័នទទួលប្រាក់បញ្ញើ | ១៦,៩% | ១៧,០% | ១៦,៦% | ១៦,៨% | ១៦,៨% | ១៧,០% | ១៧,១% | ១៧,០% | ១៦,៨% | | | |
| រូបិយបណ្ណបរទេសនៅក្នុងធនាគារ | ៨៣,១% | ៨៣,០% | ៨៣,៤% | ៨៣,២% | ៨៣,២% | ៨៣,០% | ៨២,៩% | ៨៣,០% | ៨៣,២% | | | |

ក្រាហ្វ៣.២-បម្រែបម្រួលរូបិយវត្ថុក្នុងត្រីមាសទី៣ ឆ្នាំ២០២៣

(ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)




តារាង៣.៣-ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំត្រីមាស

| *បរិយាយ* | *ត្រីមាសទី៣ ២០២៣* | *ត្រីមាសទី២ ២០២៣* | *ត្រីមាសទី៣ ២០២២* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ (ប៊ីលានរៀល)<br>ក្នុងនោះ: ជារៀល | ២២០ ០៣៧,៩<br>២៤ ១៨១,៧ | ១៩៨ ៥៤៤,០<br>២១ ៣៧១,៩ | ១៨៨ ៨៩៩,៩<br>២០ ៥១៣,៣ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ប៊ីលានរៀល) | ២១ ២៣៩,៨ | ៤០ ១៩៧,៧ | ៣៧ ៧២៤,៦ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៦% | ៦,៧% | ៥,៩% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៥,៨% | ៥,៨% | ៤,៧% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១២,០% | ១១,៧% | ១១,៥% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១០,០% | ៩,១% | ១០,៨% |
| កម្ចីជារៀលនៅអិល អូ អិល ស៊ី | ១៦,៧% | ១៨,០% | ១៨,០% |
| កម្ចីជារៀលនៅអម្រឹត | ១៧,៨% | ១៧,៩% | ១៧,៥% |
| កម្ចីជារៀលនៅប្រាសាក់ | - | ១៦,៧% | ១៦,២% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងវប្បធម៌

➡ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម

➢**កសិកម្ម**:

✓នេសាទសម្រេចបាន២០៦,៥ពាន់តោន កើនឡើង២៣,០%ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ ០,៦%ធៀបនឹង ត្រីមាសដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៤ ២៧៦,៣GWh មានការថយចុះ៣,២%ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង១៤,៥%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

– អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន២ ៨៤៤,៥GWh (ស្មើ៦៦,៥%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការកើនឡើង៩៧,៤%ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ៨,៤%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

– អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន១ ១១៧,២GWh (ស្មើ២៦,១%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការថយចុះ៥៥,១%ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៤៣៦,៨%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

– អគ្គិសនីផ្គត់ផ្គង់ដោយថាមពលពន្លឺព្រះអាទិត្យ (Solar) មានចំនួន១៨៨,៤GWh (ស្មើ៤,៤%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការថយចុះ៤,៩%ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង២០,៨%ធៀបនឹង ត្រីមាសដូចគ្នាឆ្នាំមុន។

– អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDC មានចំនួន១១៥,៧GWh (ស្មើ២,៧%នៃអគ្គិសនីសរុប ផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការថយចុះ៤៩,២%ធៀបនឹងត្រីមាសមុន និងថយចុះ៥៤,២%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

– អគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន១០,៥GWh (ស្មើ០,២%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)មានការថយចុះ៨២,៤%ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៤,០%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢ផលិតកម្មស៊ីម៉ងត៍មានចំនួន១ ៨៥០,៦ពាន់តោនមានការថយចុះ៤,១%ធៀបនឹងត្រីមាសមុន និងថយចុះ៨,១%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

តារាង៤.១- ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូចនិងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន-ត្រីមាសទី៣ ២០២៣ | ចំនួន-ត្រីមាសទី២ ២០២៣ | ចំនួន-ត្រីមាសទី៣ ២០២២ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៥១ | ៣៩ | ៥២ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ២ ០២៦ | ១ ៩៩៧ | ១ ៩៦២ |
| ▪ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បើកថ្មី) | ៣០៧ | ២៧៤ | ៣២៤ |
| ▪ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បន្ត) | ៣៩៦ | ៣៩៥ | ៤០៧ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឱ្យសាងសង់មានចំនួន៥ ១៧៣,៧ពាន់ម² មានការកើនឡើង៣៧,២%ធៀបនឹងត្រីមាសមុន និងកើនឡើង១៦២,៣%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង២ ២០០,២លានដុល្លារមានការកើនឡើង៤៩,២%ធៀបនឹងត្រីមាសមុន និងកើនឡើង១៩៧,២%បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

តារាង៤.២- សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| បរិយាយ | ពាន់ម² — ត្រីមាសទី៣ ២០២៣ | ពាន់ម² —ត្រីមាសទី២ ២០២៣ | ពាន់ម² —ត្រីមាសទី ៣ ២០២២ |
|---|---|---|---|
| ▪ លំនៅឋាន | ៣ ០៦១,២ | ១ ៦៩០,៧ | ១ ០៦៧,៩ |
| ▪ ឧស្សាហកម្ម | ១ ០៨៩,៨ | ១ ២៨៧,៧ | ៥៦៦,៦ |
| ▪ពាណិជ្ជកម្ម | ៨៦៣,២ | ៤២១,០ | ១១៩,៧ |
| ▪ ទេសចរណ៍ | ៧៦,៦ | ១៣៧,៧ | ៥,៨ |
| ▪ផ្សេងៗ | ៦,១ | ០,០ | ០,០ |
| អនុញ្ញាតសរុប | ៥ ១៧៣,៧ | ៣ ៧៧១,៣ | ១ ៩៧២,៣ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាត្រីមាសនេះ គឺលំនៅឋាន៥៩,២% និងឧស្សាហកម្ម២១,១%នៃផ្ទៃក្រឡាសរុប។

➢**សេវាកម្ម**

តារាង៤.៣-ការចុះបញ្ជីនិងលុបចេញពីបញ្ជីនៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន —ត្រីមាសទី ៣ ២០២៣ | ចំនួន—ត្រីមាសទី ២ ២០២៣ | ចំនួន—ត្រីមាសទី ៣ ២០២២ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១ ២០៨ | ១ ២៤៣ | ១ ៣៦០ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២៦៦ | ២១១ | ២៣២ |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ១ ៣៦៣ | ១ ៤២៣ | ១ ៥១០ |
| ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិច | ៦ | ៤៥ | ៦ ២០៧ |
| ក្នុងនោះ លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | ២ | ២៨ | ៥ ៥៧៣ |

➢**ការងារ**

តារាង៤.៤- ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់—ត្រីមាស ទី៣ ២០២៣ | នាក់—ត្រីមាស ទី២ ២០២៣ | នាក់—ត្រីមាស ទី៣-២០២២ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ( ទីភ្នាក់ងារជាតិមុខរបបនិងការងារ) | ៧ ៧៦៥ | ៨ ៥៥៦ | ២ ៦៥៣ |
| អ្នកទទួលបានការងារធ្វើតាមរយៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ១០៣ ៦៥១ | ៨៧ ១៦៥ | ១៥១ ៣៧៨ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៨៥ ៦៤៨ | ៧៥ ៥៦៧ | ១៤១ ២៦៦ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៨ ០០៣ | ១១ ៥៩៨ | ១០ ១១២ |

## ➢ វិនិយោគ

តារាង៤.៥-គម្រោងវិនិយោគអនុញ្ញាតដោយក.អ.ក.(ថ្មីនិងពង្រីក)

| ប្រភេទ | ត្រីមាសទី៣ ២០២៣ | ត្រីមាសទី២ ២០២៣ | ត្រីមាសទី៣ ២០២២ |
|---|---|---|---|
| អនុញ្ញាតសរុប(លានដុល្លារ) | ២ ៦៥៩,៧ | ៨១១,៦ | ៤៦០,៨ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១៦៥,១ | ១៦៣,៥ | ០,០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខរបស់តំបន់សេដ្ឋកិច្ចពិសេស) | ៩៤២,៨ (៣៣៤,៣) | ៥៩៦,៧ (២៥៩,៥) | ៣៦១,៥ (១៩៤,៥) |
| វិស័យទេសចរណ៍ | ៨៤,៥ | ៣៧,៥ | ៣៥,៣ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១ ៤៦៧,២ | ១៤,០ | ៦៤,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៧៨ | ៧៤ | ៥២ |
| បង្កើតការងារ (ពាន់នាក់) | ១០៤,៥ | ៧៥,២ | ៤០,៦ |

➢ **ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន៣ ៨៩៨,៧ ពាន់តោន មានការកើនឡើង ១០,១%ធៀបនឹងត្រីមាសមុន និងកើនឡើង៣០,៦%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ក្នុងនោះ៖

តារាង៤.៦-ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ(ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)

| | |
|---|---|
| កំពង់ផែភ្នំពេញ: +២៥,៥% | (+៣៨,៩%) |
| កំពង់ផែកំពង់សោម: +៣,៥% | (+២៦,៦%) |

## ➢ ការចុះបញ្ជីនិងចរាចរណ៍

តារាង៤.៧-ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ចំនួន—ត្រីមាសទី ៣ ២០២៣ | ចំនួន—ត្រីមាស ទី២ ២០២២ | ចំនួន—ត្រីមាស ទី៣ ២០២២ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី(ពាន់គ្រឿង) | ៦៤,២ | ៧៦,១ | ៩៩,៧ |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ១២,១ | ១៥,៥ | ២៣,៧ |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍(លើក) | ៨៨០ | ៨០៦ | ៦៧៧ |

## ➢ ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %∆ ធៀបនឹងត្រីមាសមុន | %∆ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៣៨,៤ | +២២,៤% | +៣៥,៩% |
| ក្នុងនោះទទួល | ១០,៤ | +១៦,៩% | +២,៥% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១០១,១ | +៤,២% | +៤៦,៩% |
| ក្នុងនោះទទួល | ៥២,២ | -០,២% | +១៩,៦% |

| ប្រភេទ | ចំនួន | %Δ ធៀបនឹងត្រីមាសមុន | %Δ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១ ៤១២,៨ | +១,៩% | -១៣,៧% |
| ក្នុងនោះហៅចូល | ៤៤៥,៣ | -៣,៤% | -៣៥,១% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៥ ៤៤៩,២ | +៩៧,៦% | +៣៣,២% |
| ក្នុងនោះហៅចូល | ៥ ៤២៤,៣ | +១០៣,១% | +៣៤,៨% |

➢ **ការធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍**

តារាង៤.៨-អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងត្រីមាសមុន | %Δ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៦,៦ | -៩,៤% | +៣៥,៤% |
| ភ្ញៀវទេសចរបរទេសទិញបណ្ណទស្សនាអង្គរ | ១៥៣,៨ | +២,៩% | +១០៧,៤% |
| ភ្ញៀវទេសចរបរទេសចូលទស្សនារមណីយដ្ឋានព្រះវិហារ | ១,៨ | +១១,៨% | +៨២,៨% |
| អ្នកដំណើរតាមផ្លូវអាកាស(ក្នុងស្រុក) | ៣៥,៨ | -១៨,៨% | +២៦,៩% |
| អ្នកដំណើរតាមផ្លូវអាកាស(អន្តរជាតិ) | ១ ១៦១,៧ | -០,១% | +៦៥,០% |
| ទំនិញដឹកជញ្ជូនតាមផ្លូវអាកាស | ១៦,០ | +១៦,០% | +២១,៧% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៤៥៨,៦ | +១,១% | +២៧,៦% |
| ចំនួនទេសចរផ្ទៃក្នុង | ២ ៥៤៣,០ | -៥៨,៨% | -៣,៩% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ១ ៣៤៧,០ | +៤,៥% | +៧៧,៥% |
| ✓ តាមផ្លូវអាកាស | ៤២៧,៩ | -០,៨% | +៨៧,៥% |
| ✓ តាមផ្លូវគោកនិងផ្លូវទឹក | ៩១៩,១ | +៧,២% | +៧៣,២% |

## ៥. ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាត្រីមាសទី៣ ឆ្នាំ២០២៣ មានចំនួន២៣ ០៨៧,៦ប៊ីលានរៀល (ស្មើនឹង៥ ៦០១,១ លានដុល្លារ) ថយចុះ៧,០%ធៀបនឹងត្រីមាសមុន និងថយចុះ២៤,០%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១-បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δ ធៀបនឹងត្រីមាសមុន | %Δ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|
| ប្រេងសាំង | +១៤,៧% | +២២,៧% |
| ប្រេងម៉ាស៊ូត | -០,៣% | +៨,៣% |
| ឧស្ម័ន | +២៧,៦% | +១៨,៨% |

| ទំនិញ | %Δ ធៀបនឹងត្រីមាសមុន | %Δ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|
| គ្គិសនីនាំចូលដោយ EDC | -៤៩,២% | -៥៤,២% |
| ដែកសំណង់ | -៩,៥% | +១៥,០% |
| ស៊ីម៉ងត៍ | +១៧,១% | +៦៣,៣% |
| ជីកសិកម្ម | -៥,៥% | +៦២,៨% |
| នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម | +១១,៣% | +៥៥,៨% |
| រថយន្តសរុប (ប៊ី.ល.រ) | -១៦,២% | -៥៤,៩% |
| រថយន្តសរុប (គ្រឿង) | -៣,៦% | -៦៣,១% |
| ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -៦,៣% | -៦០,៩% |
| ស្រូវសាលី | -២៩,២% | +៥,០% |
| ផ្លែឈើនិងបន្លែ | +២៥,៤% | +១៩២,៨% |
| ថ្នាំកសិកម្ម | -១០,៩% | +១៤,០% |
| នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -៥,៩% | +៩,០% |

➡ **ការនាំចេញ** ត្រីមាសទី៣ ឆ្នាំ២០២៣ មានចំនួន២៣ ៥៦៨,៥ប៊ីលានរៀល ស្មើនឹង៥ ៧១៧,៧លានដុល្លារ (១០២,១% នៃការនាំចូល)កើនឡើង០,៤%ធៀបនឹងត្រីមាសមុន និងកើនឡើង២,៧%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង៥.២-បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %Δ ធៀបនឹងត្រីមាសមុន | %Δ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|
| ផលិតផលឈើកែច្នៃ | -៥២,២% | -៦៦,៦% |
| វាយនភណ្ឌនិងស្បែកជើង | +៧,៧% | -១៥,១% |
| អង្ករ | -១២,៨% | +៣,៣% |
| ផលិតផលនេសាទ | +១១,១% | +៣៣,៨% |
| កៅស៊ូ | +៦៦,៩% | +៤១,២% |

# ការសិក្សាស្រាវជ្រាវសាគរសាស្រ្ត និងធនធានជលផល នៅសមុទ្រកម្ពុជាឆ្នាំ១៩៨៣-១៩៨៦ (តចប់)

៥.៣.៥សមាសភាពរបាយនិងចរិតលក្ខណៈសត្វគ្មានឆ្អឹងកង (Invertebrates)

**សិរបាតសត្វ** (Cephalopods) នៅអំឡុងពេលស្រាវជ្រាវនៅសមុទ្រកម្ពុជាពពួកសត្វគ្មានឆ្អឹងខ្នងបានបង្ហាញភាពសំខាន់របស់ពួកវា នៅក្នុងសេដ្ឋ- កិច្ចសមុទ្រដែរ។ ចាប់ពីឆ្នាំ១៩៨៣ ដល់ឆ្នាំ ១៩៨៦ នៅក្នុងផលនេសាទគេតែងប្រទះឃើញ មឹកបំពង់ (calmar) ៣ប្រភេទ៖ មឹកបំពង់ស្លាបខ្លី (Loligo duvauceli) មឹកបំពង់ស្លាបវែង (Dorytheuthis singhalensis) មឹកបំពង់ហ៊ុយសាយ (Sepiotheuthis lessoniana) និង មឹងស្នូក (cuttle fish) ៥ប្រភេទ៖ មឹកព្រះថៅ (Sepia pharaonis), មឹកស្នូកមាស (Sepia esculenta) មឹកស្នូក (Sepia lycidas) មឹកបន្លា (Sepia recurvirostra) មឹកខ្មោចឬមឹកកន្ទុយកាត់ (Euprymna sp.) និងមឹកពីងពាង (octopus) ១ប្រភេទ៖ មឹកពីងពាង (Scaengrus octopus)។

មឹកបំពង់២ប្រភេទខាងលើជាប្រភេទដែលបង្ហាញខ្លួនញឹកញាប់ ឯសិរបាតសត្វផ្សេងទៀតមិនសូវបង្ហាញខ្លួនញឹកញាប់ទេ។ របាយនៃសិរបាតសត្វតាមរដូវខុសៗគ្នាជាលក្ខណៈផ្តុំហ្វូងតូចៗ។សត្វទាំងនោះ ត្រូវបានប្រទះឃើញនៅទូទាំងតំបន់ ដែលបានសិក្សាស្រាវជ្រាវ ស្ទើរគ្រប់តំបន់ជំរៅទឹក (១៥-៨០ម៉ែត្រ) នៃសមុទ្រកម្ពុជា។ ផលនេសាទសត្វប្រភេទទាំងនេះ មានមិនលើសពី ២-៥គក្រ/ម៉ោង នៃការនេសាទអួនអូសពិសោធន៍ឡើយ។ការប្រមូលផ្តុំយ៉ាងណែននៃពពួកសត្វនេះត្រូវបានដឹងតាមផលនេសាទដោយការអូសអួនរយៈពេលមួយម៉ោងចាប់បានពី២៥-៣៥គោន ដែលកើតឡើងដោយចៃដន្យ។

ការប្រមូលផ្តុំហ្វូងច្រើននៃសិរបាតសត្វត្រូវបានប្រទះឃើញនៅតំបន់ជិតខាងកោះសារ៉ូវី កោះតាង កោះព្រីង និងកោះវៃ ដែលនៅភាគខាងត្បូងនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខកម្ពុជា។ ផលចាប់តាមការអូសអួនមួយម៉ោងមានមិនលើសពី៥គក្រឡើយ។ ផលចាប់បានជាអតិបរិមាគឺ ២០គក្រ/ម៉ោង នៅតំបន់កោះ។ គេអាចប៉ាន់ស្មានបានថា មឹកបំពង់ បង្ករការ ប្រមូលផ្តុំហ្វូងធំនៅអំឡុងខែកុម្ភៈ-មិនា។ នៅអំឡុងខែមិនា-មេសា សិរបាតសត្វទាំងនោះចាប់ផ្តើមបាត់មុខស្ទើរតែទាំងស្រុងពីផលនេសាទដែលបានពីការអូសអួន (តាមការស្រាវជ្រាវ) ជាពិសេសពពួកមឹកបំពង់ (រូបភាព១០, ១១, ១២, ១៣)។

**សត្វទឹកមានសំបករឹង** (Crustacean) ការស្រាវជ្រាវរកឃើញថាមានសត្វទឹកសំបករឹងទាំងអស់ចំនួន១១ប្រភេទនៅសមុទ្រកម្ពុជា ដែលក្នុងនោះមាន២ប្រភេទក្នុងអម្បូរ បង្កងប៉ាក (Seyllaridae)៖ បង្កងប៉ាក (Thenus orientalis) និងបង្កងប៉ាក (Seyllarus sp.) ដែលបានជួបនិងធ្វើអង្កេតបានពីរបីដងប៉ុណ្ណោះ ឯប្រាំបួនប្រភេទទៀត គឺជាប្រភេទបង្គានៃអម្បូរ Penaeidae ៖ បង្គាខ្លឹងខ្មៅ (Penaeus monodon) បង្គាស (Penaeus merguiensis) បង្គាប៉ាវ៉ា (Penaeus latisulcatus) បង្គាខ្លឹង (Penaeus semisulcatus) បង្គានីឡុង (Metapenaeus intermedius) និងបង្គា៤ប្រភេទទៀតដែលមិនទាន់បានសិក្សាកំណត់ឈ្មោះវិទ្យាសាស្រ្ត។

បង្កងប៉ាក (Seyllaridae) ត្រូវបានប្រទះឃើញក្នុងផលនេសាទដែលចាប់បាននៅពេលថ្ងៃដែលផលអតិបរិមាគឺចាប់បាននៅពេលយប់ ឯបង្គាអាចចាប់បានតែនៅពេលល្ងាច និងយប់ប៉ុណ្ណោះ។ បង្កងប៉ាកប្រភេទ (Thenus orientalis) ជាប្រភេទដែលសម្បូរជាងគេក្នុងចំណោមសត្វមានសំបករឹងនៅសមុទ្រកម្ពុជា។ការប្រមូលផ្តុំហ្វូងនៃពពួកបង្កងប៉ាកត្រូវបានប្រទះឃើញនៅតំបន់កោះរ៉ុង និងកោះជិតឆកកំពង់សោម នៅជំរៅទឹកពី ២០ - ១៥ម៉ែត្រ។ ផលនេសាទអតិបរិមានៃប្រភេទសត្វនេះគឺ៧-៨គក្រ/ម៉ោងនៃការនេសាទអួនអូស។ទំហំអតិបរិមានៃបង្កងប៉ាកនៅក្នុង



រូបភាព១០. ផែនទីបង្ហាញកំរិតប្រមូលផ្តុំនៃសិរបាទសត្វខែកុម្ភៈមិនា



រូបភាព១១. ផែនទីបង្ហាញកំរិតប្រមូលផ្តុំនៃសិរបាទសត្វខែមិនាមេសា



រូបភាព១២. ផែនទីបង្ហាញកំរិតប្រមូលផ្តុំនៃសិរបាទសត្វឧសភា-កក្កដា)



រូបភាព១៣. ផែនទីបង្ហាញកំរិតប្រមូលផ្តុំនៃសិរបាទសត្វកក្កដា-សីហា)

## ពណ៌បង្ហាញពីរបាយកំរិតប្រមូលផ្តុំនៃត្រី



កំរិតប្រមូលផ្តុំខ្ពស់បំផុត
(ផលចាប់ជាមធ្យមក្នុងមួយសារយៈ
ពេលមួយម៉ោង ១០០ហឹប )

កំរិតប្រមូលផ្តុំទាបបំផុត
(ផលចាប់ជាមធ្យមក្នុងមួយសារយៈ
ពេលមួយម៉ោង ១០គីឡូក្រាម



រូបភាព១៤. ផែនទីបង្ហាញកំរិតប្រមូលផ្តុំនៃបឹកបំពង់ខ្លី (កុម្ភៈមិនា)



រូបភាព១៥. ផែនទីបង្ហាញកំរិតប្រមូលផ្តុំនៃបឹកបំពង់ខ្លី (មិនាមេសា)



រូបភាព១៦. ផែនទីបង្ហាញពីកិច្ចប្រមូលផ្តុំនៃមឹកហ៊ីយសាយ(កុម្ភៈមិនា)



រូបភាព១៧. ផែនទីបង្ហាញពីកិច្ចប្រមូលផ្តុំនៃមឹកហ៊ីយសាយ(មិនាមេសា)



រូបភាព១៨ ផែនទីបង្ហាញពីកិច្ចប្រមូលផ្តុំនៃមឹកស្លូក (កុម្ភៈមិនា)



រូបភាព១៩ ផែនទីបង្ហាញពីកិច្ចប្រមូលផ្តុំនៃមឹកស្លូក (មិនាមេសា)

តំបន់ ( ទំហំទីផ្សា ) គឺ ២២៥មម តែសមាសភាពទំហំខុសប្លែកគ្នា ត្រូវបានសង្កេតឃើញដូចតទៅ៖ នៅខែកុម្ភៈ បង្កងប៉ាកជាង៥០% ទំហំពី១២០-១៥០មម នៅខែមេសា បរិមាណបង្កងប៉ាកធំៗ បានថយចុះ តែបង្កងប៉ាកក្មេងៗ ទំហំ ៩៥-១១០មម បានកើនឡើង ២០% នៃបរិមាណសរុប។ បង្កងប៉ាកញីមានទំហំធំជាងឈ្មោលឯទំហំមធ្យមតាមការសង្កេតពីដំណាក់កាលមួយទៅមួយគឺ១៥០,១៥៨,១២១-១២៤មម។ នៅអំឡុងខែមិនា-មេសា បរិមាណបង្កងប៉ាកញីមានចំនួនតិចជាងឈ្មោល តែមានក្រពេញបន្តពូជគ្រប់ដំណាក់កាលនៃការបន្តពូជ។ អត្រាភេទឈ្មោលញីតាមដំណាក់កាលបន្តពូជ ប្រែប្រួលទៅតាមពេលវេលា ដូចជានៅអំឡុងខែកុម្ភៈ-មិនា បង្កងប៉ាកគ្មានពងមានចំនួន១៤% តែរហូតមកដល់ខែមេសា ចំនួនត្រូវបានថយចុះមក ៩% ឯបង្កងប៉ាកដែលចាប់ផ្តើមករពងកើនឡើងដល់២១%និងពួកដែលមានពងជិតញាស់មានចំនួន ១៩% ហើយបង្កងប៉ាកមេដែលបញ្ចេញកូនកើនឡើងដល់៥១%។គេអាចប៉ាន់ស្មានបានថាការទម្លាក់កូនរបស់បង្កងប៉ាកគឺនៅតំបន់នោះក្នុងរយៈកាលដ៏វែង ហើយការទម្លាក់កូនដ៏សម្បើមកើតឡើងនៅអំឡុងចុងខែវិច្ឆិកា-មេសា។ ស្តុកបង្កងប៉ាកនៅសមុទ្រកម្ពុជាមានពី២៥-៣៥តោនប៉ុណ្ណោះ។ បង្គាត្រូវបានរកឃើញថាមិនសូវសម្បូរចំពោះប្រភេទខ្លះនៃបង្គា បើតាមការអង្កេតទៅលើផលបង្គា ដែលនេសាទបាន ដោយឈរលើមូលដ្ឋាននៃបង្គាគ្រប់ប្រភេទ។ភាគច្រើននៃបង្គាទាំងនោះត្រូវនេសាទបាននៅតំបន់ឆ្នេរ នាទីខ្ពស់ក្រោមទឹកនៅគ្រប់រដូវ។ នៅអំឡុងពេលសិក្សា ការប្រមូលផ្តុំហ្វូងជាទូទៅ គឺនៅទីតាំងដដែលៗ ចាប់ពីកោះកុងនៅភាគខាងជើងមកកោះព្រីងភាគនារតីបន្តទៅឆករាមនៅភាគខាងកើត

### តារាង១២. សន្ទស្សន៍ជីវសាស្ត្រ/ទំហំទម្ងន់និងអត្រាភេទនៃសត្វគ្មានឆ្អឹងកងនៅតំបន់សេដ្ឋកិច្ចផ្តាច់មុខកម្ពុជា

| ប្រភេទសត្វ | ទំហំមធ្យម (មីលីម៉ែត្រ) | ទម្ងន់មធ្យម (ក្រាម) | អត្រាភេទ |
|---|---|---|---|
| មឹកបំពង់ស្លាបខ្លី | ១៩៦.២ ± ០.៩៩ 　 ១១១.៧ ± ០.៨៨ | ៦៨៩.១ ± ០.៨៧ 　 ៥១.៥ ៣.០០ | ២២.២ : ១.០ 　 ១.៦ : ១.០ |
| មឹកបំពង់ស្លាបវែង | ១៦៩.៨ ± ១.៨៨ 　 ១៧១.៥ ± ១.៨៥ | ១២៣.៣ ± ៣.២៦ 　 ១២៣.៣ ± ២.៤៤ | ០.៥ : ១.០ 　 ០.៣ : ១.០ |
| មឹកហ៊ុយសាយ | ១៧៨.១ ± ៤.៣៦ 　 ១៥៨.២ ± ២.៨៦ | ៣៥៣.៦ ± ១៩.១៨ 　 ២៦៣.៩ ± ១០.៨២ | ១.២ : ១.០ 　 ១.៣ : ១.០ |
| មឹកស្នូកមាស | ១០៧.៤ ± ៣.៣៤ 　 ១០៦.៧ ± ១.៦៦ | ១៤៣.៦ ± ១១.៦ 　 ១៤០.៥ ± ៥.៥៩ | ៤.២ : ១.០ 　 ៣.១ : ១.០ |
| មឹកព្រះថៅ | ១៣៨.១ ± ១០.៣១ 　 ១០១.៨ ± ៤.៣០ | ៣៦៣.៦ ± ៦០.១៤ 　 ១៤៩.១ ± ២០.៣៥ | ១.២ : ១.០ 　 ០.៦ : ១.០ |
| បង្កងប៉ាក | ១៣៧.៥ ± ១.១០ 　 ១៣៥.៣ ± ១.២១ | ១០៧.៣ ± ២.៣០ 　 ១០៣.៤ ± ២.៤៣ | ០.៦ : ១.០ 　 ១.០ : ១.០ |
| បង្គាខ្លឹងខ្មៅ | ១៨០.៨ ± ១.៣៣ 　 ១៤២.៣ ± ១.៥២ | ៨២.៩ ± ៣.១០ 　 ៨៨.៩ ± ៣.១០ | ០.៤ : ១.០ 　 ០៤ : ១.០ |
| បង្គាប៉ាវ៉ា | ១៣៨.២ ± ១.៣៣ 　 ១៤២.៣ ± ១.៥២ | ៣៨.២ ± ១.២៦ 　 ៣២.៦ ± ០.៨១ | ១.១ : ១.០ 　 ១.៦ : ១.០ |
| បង្គាខ្លឹង | ១៣៨.៥ ± ១.៥១ 　 ១៣៥.៦ ± ១.៥៨ | ៣៥.៥ ± ១.០៥ 　 ៣៤.២ ± ០.៦៤ | ១.២ : ១.០ 　 ១.០ : ១.០ |
| បង្គាប៉ាវ៉ាខ្មៅ | - 　 ១៣០.៧ ± ៦.២៨ | - 　 ១៨.៩ ± ០.៨២ | - 　 ១.០ : ១.០ |
| បង្គានីឡុង | ៧៣.៣ ± ១.៣០ 　 - | ៥.៩ ± ០.៣៦ 　 - | ១.០ : ១.០ 　 - |
| បង្គា ១ | ១២៣.៣ ± ១.២៦ 　 ១២៣.៤ ± ១.២៤ | ២៥.៦ ± ០.៧០ 　 ២៦.២ ± ០.៥៧ | ១.៤ ១.០ 　 ១.២ ១.០ |
| បង្គា ២ | ១០០.២ ± ១.៥៤ 　 ១០៦.៣ ± ១.១៧ | ១៤.៩ ± ០.៦០ 　 ១៣.៣ ± ០.២៤ | ២.២ ១.០ 　 ១.៧ ១.០ |

នៃតំបន់។

នៅខែកុម្ភៈ ផ្ទៃក្រឡានៃតំបន់ប្រមូលផ្តុំហ្វូងបង្គារីកឡើង៣ដងតែផលបង្គាដែលនេសាទដោយការអូសអួនរយៈពេលមួយម៉ោង ដែលបានច្រើននោះគឺនៅអំឡុងខែមិនា-មេសា ដោយនៅខែកុម្ភៈ អូសអួនមួយម៉ោងបានបង្គា០.៩គ្រ ឯនៅខែមេសា អូសអួនដូចគ្នាទទួលបានបង្គា១.៨គក្រ។ តែបើតាមទិន្នន័យដែលកត់ត្រានៅអំឡុងខែកក្កដា-សីហា ឆ្នាំ១៩៨៣ ការនេសាទដូចគ្នានេះ អនុវត្តនៅម៉ុំមាត់ឆកកំពង់សោម បានផ្តល់ផលបង្គាពី៣-៦គក្រ។ បង្គាប៉ាវ៉ាត្រូវបានជួបញឹកញាប់ជាងគេ គួបផ្សំជាមួយបង្គាខ្លឹង និងបង្គាខ្លឹងខ្មៅផងនោះពួកវាបានក្លាយជាផលបង្គាដែលចាប់បានជាចំបង។ ទំហំនិងទម្ងន់បង្គាប្រែប្រួលរៀងខ្លួនពី១៤០-១៨០មមនិងពី៣២-៩០ក្រ។ អត្រាភេទឈ្មោលញី គឺបានប្រែប្រួលទៅតាមប្រភេទខុសគ្នាដូចតទៅៈ០.៧:១.០ ១.៩:១.០។ គេមិនដែលប្រទះឃើញបង្គាមេមានពងជាប់ពោះនៅអំឡុងពេលស្រាវជាវឡើយ។ បង្គាញីជាធម្មតាតែងតែធំជាងឈ្មោលនៅក្នុងរង្វង់នៃការប្រមូលផ្តុំហ្វូងបង្គា។ស្តុកបង្គាមានពី ២០-៤០តោន ប៉ុណ្ណោះ។

ប្លង់តុង (plankton) ការស្រាវជ្រាវខាងបរិមាណបានបង្ហាញជាទូទៅថាបរិមាណជីវម៉ាស់នៃប្លង់តុង កើនឡើងពីភាគខាងលិច ទៅភាគឥសាន្តនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខកម្ពុជាដោយសារចរន្តទឹកមិនសូវប្រែដែល សម្បូរវត្ថុធាតុជីវពន្ធ ហូរចេញពីទ្វីបតាមទន្លេ ស្ទឹងជាច្រើន ចាក់ចូលឆកកំពង់សោម។ បរិមាណជីវម៉ាស់ ប្រែប្រួលទៅតាមមុខងារនៃរដូវ។ អំឡុងខែកុម្ភៈ-មេសា ជីវម៉ាស់មាន ៤,៥០០មក្រ/ម៣ អំឡុងខែឧសភា-កក្កដាជីវម៉ាស់មាន៤,៦០០មក្រ/ម៣ និងអំឡុងខែកក្កដា-សីហា ជីវម៉ាស់មាន ២១,៨០០ មក្រ/ម៣ (រូបភាព ២០, ២១, ២២, ២៣, ២៤)។

ហ្វីតូប្លង់តុងនិងសិលាកំទិចកំណត់ណាងភាគមួយដ៏សំខាន់នៃជីវម៉ាស់ក្នុងតំបន់ក្បែរឆ្នេរ។បរិមាណឌីយ៉ាតូមមានចំនួនលើសលប់នៅតំបន់ក្បែរឆ្នេរក្នុងចន្លោះជំរៅទឹក២០-៤០ម៉ែត្រ។នៅភាគខាងជើងនិងខាងកើត នៃតំបន់ស្រាវជ្រាវ គេប្រទះឃើញកូនបង្គាយ៉ាងសម្បើម។ នៅឆ្ងាយពីច្រាំង អត្រាហ្វីតូប្លង់តុងបានថយចុះពី៣-៥%តែបរិមាណសសិលាកំទិចកំណាបានកើនឡើង។ ហ្សូអូប្លង់តុងបង្ហាញខ្លួនជិត៣០% នៃជីវម៉ាស់ក្នុងភាគធំនៃតំបន់សមុទ្រកម្ពុជា។ អត្រាធម្មតាមានមិនលើសពី៥-១០%ឡើយ។ផ្នែកសំខាន់នៃហ្សូអូប្លង់តុងមានៈ Decapoda, Amphipoda, Chaetognata ហើយនឹងមាននៅ Hydromedusa, ពងត្រី និងកូនត្រីម្សៅផងដែរ។

### ៥.៤ សេចក្តីសន្និដ្ឋាន

១. ស្តុកត្រីនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ នៃ



រូបភាព២០ ផែនទីបង្ហាញរបាយកំរិតជីវម៉ាស់សរុបនៅស្រទាប់បាតក្នុងដែនកម្ពុជា



រូបភាព២១ ផែនទីបង្ហាញពីរបាយកំរិតជីវម៉ាស់សរុបនៅផ្ទៃលើ ក្នុងដែនកម្ពុជា



រូបភាព២២, ផែនទីបង្ហាញរបាយកំរិតជីវម៉ាស់សរុបជិតស្រទាប់បាតក្នុងដែនកម្ពុជា






រូបភាព២៣ ផែនទីបង្ហាញពីរបាយកំរិតជីវម៉ាស់ប្លង់តុង នៅខែកុម្ភៈមិនា



រូបភាព២៤ ផែនទីបង្ហាញពីរបាយកំរិតជីវម៉ាស់ប្លង់តុង នៅខែមិនាមេសា

សមុទ្រកម្ពុជា ត្រូវបានប៉ាន់ស្មានថា មាន ៥០០០០ តោន ដែលតាមថាមពលនៃការបន្តពូជ (population dynamic) នៅក្នុងលក្ខខណ្ឌនៃប្រព័ន្ធអេកូឡូស៊ី នៅអំឡុងពេលនោះ អាចអនុញ្ញាតឲ្យប្រមូលផល ពី ២០,០០០ ទៅ ២២,០០០តោន/ឆ្នាំ ដើម្បីជានាចីរភាពធនធាននេះ។

២. នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ នៃសមុទ្រកម្ពុជាធនធានមានជីវិតដែលគួរឲ្យចាប់អារម្មណ៍បំផុតក្រៅពីត្រី គឺ សិរបាតសត្វ (cephalopods) ដែលស្តុករបស់វាមានពី ៨០០ ទៅ ១៣០០តោន ។

៣. ស្តុកសត្វទឹកមានសំបករឹង (crustacean) នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខកម្ពុជានៃឈូងសមុទ្រថៃ មិនសូវសម្បូរទេ។

ដោយ ទូច ស៊ាងតាណា

## ១- ជ្រុងមួយនៃភាសាខ្មែរ ៖ ចម្ងល់យើងចំពោះពាក្យខ្មែរមាន « រ » ( តចប់ )

គ.សភាពផ្ទុយគ្នារវាងអំណាននិងសំណេរ

១.អំណានរូបស័ព្ទមានទម្រង់ប្រហែលគ្នា:ក្នុងភាសាខ្មែរយើង គេឃើញអំណានពាក្យមានស្នូរខុសគ្នា ថ្វីបើរូបស័ព្ទរបស់ពាក្យមានលំនាំដូចគ្នា។ ពាក្យទាំងនោះគឺ ៖ ស្ដាយ ស្ដោក សន្ដោស បន្ដ អន្ដរធាន អន្ដរជាតិ ...

២.សំណេរផ្ទុយនឹងអំណាន : គេឃើញពាក្យជាច្រើននៅក្នុងភាសាខ្មែរយើង មានសំណេរខុសគ្នាពីអំណានហើយពុំទាន់មានក្បួនខ្នាតបញ្ជាក់ឱ្យច្បាស់លាស់នៅឡើយ។យើងសូមលើកយកមកបង្ហាញខ្លះនូវពាក្យដូចតទៅនេះ ស្នូរអំណានថា ៖

| | | |
|---|---|---|
| - ផ្ដាច់ញ៉ា | សំណេរជា | ប្ដេជ្ញា |
| - មីន៉ា | - | មីនា |
| - ហៃត | - | ហេតុ |
| - ខែត | - | ខេត្ត |
| - តុក | - | តុ |
| - ប៉ាក់ដិសែត | - | បដិសេធ |
| - ប្រ៉ធាន | - | ប្រធាន |
| - សំដាច់ | - | សម្ដេច |
| - ម្ដិច | - | ម្ដេច |
| - ខ្វិច | - | ខ្វេច |
| - ឡិច | - | លិច ( ទិស ) |
| - ប្រ៉យ៉ោច | - | ប្រយោជន៍...។ |

បែបទាំងពីរខាងលើនេះហាក់ដូចជាស្មុគស្មាញណាស់នៅក្នុងភាសាខ្មែរយើង។ គេគប្បីសិក្សាសាកល្បងរកនូវទំនាស់ទាំងនោះ តើបណ្ដាលមកពីអ្វី? ហើយតើត្រូវដោះស្រាយដោយរបៀបណាទើបភាសាយើងរកច្រកឃើញ? ច្រកដែលយើងបម្រុងឱ្យចេញនេះ មានវិបត្តិយ៉ាងណាដែរ? នេះគ្រាន់តែជាសំនួរដេញដោលរក ហេតុផលនៃភាសា និងដំណោះស្រាយខ្លះៗរបស់យើង។

សំណើរើអំណាន និងសំណេររបស់ចម្ងល់យើងគ្រាន់តែបង្ហាញនូវលក្ខណៈខ្លះដែលមានរួចមកហើយ។ ប៉ុន្តែគេនៅយល់ថា នេះជាធម្មតារបស់ភាសាតែងមានលក្ខណៈផ្ទុយគ្នាខ្លះយ៉ាងនេះ។គំនិតបែបខាងលើនេះបានសេចក្ដីថាគេមិនចង់កែសម្រួលការលំបាក ដែលមានមកក្នុងភាសាខ្មែរយើងនោះទេ គឺគេចង់រក្សាទុកឱ្យនៅដដែលចុះ។ បញ្ហានេះ យើងងាកមើលទៅក្រោយតើដូនតាយើងបានកែតំរូវភាសារបស់យើងប៉ុន្មានសាមកហើយ។ កំណែនោះបានល្អគ្រប់សព្វហើយឬនៅ? កំណែតម្រូវ តើតម្រូវចិត្តខ្មែរសម័យណាកំណែក្នុងសម័យនោះ? ចុះខ្មែរយើងសម័យនេះ ជាសម័យខ្មែរក្រោក ឬខ្មែរដេក? «ការក្រោក = កម្រោក» នៃគំនិតខ្មែរសម័យតេជោសែនមានល្បឿននិងសន្ទុះបានដល់ត្រឹមណាហើយតើត្រូវតាមចំណង់ចំណូលចិត្តខ្មែរយើងនវសម័យដែរឬទេ?

នេះជាចម្ងល់យើងទាំងអស់គ្នាត្រូវគិតពិចារណា។ ចម្ងល់យើងមានហើយចំពោះភាសាយើង។ យើងត្រូវកែប្រែអោយស្របស្រួលតាមសេចក្ដីត្រូវការរបស់យើងផង ពីព្រោះសព្វថ្ងៃយើងបង្កើតវិទ្យាសាស្ត្រ តិចនិចជាភាសាខ្មែរច្រើនណាស់។ ដូចនេះយើងគួររៀបចំភាសារបស់យើង ឱ្យស្របតាមកាលៈទេសៈ ប្រទេសកំពុងត្រូវការភាសាខ្មែរធ្វើជាយានសម្រាប់យកទៅសិក្សាមុខវិជ្ជានានា។តាមគំនិតយើងយល់ថា យើងគួរមានយោបល់ទូលំទូលាយ មិនគួរចង្អៀតចង្អល់ក្នុងចិត្តទេ។ អ្នកខ្លះមានការតឹងទ្រូងក្នុងបញ្ហានេះប្រហែលជាមានកម្លាចថានាំឱ្យមានសង្គ្រាមអក្សរសាស្ត្រ។ សូមបញ្ជាក់ថា បញ្ហានេះជា « ការសាកល្បងនៃការសិក្សារបស់យើងទេ» មិនមែនជាច្បាប់អាជ្ញាដាក់ឱ្យប្រើប្រើប្រាស់ជាទូទៅឡើយ។

ឃ. យោបល់ខ្ញុំ :

គួរគិតមើល ប្រិយមិត្តអ្នកសិក្សាខ្មែរទាំងអស់គ្នា។ខ្ញុំគិតព្រោះវេយ្យា ករណ៍ខ្មែរពុំមែនរបស់ខ្ញុំហើយខ្ញុំជាខ្មែរ។

តើគួរប្រើអក្សរ « ណ » ក្នុងការសរសេរពាក្យខ្មែរដែរឬទេ?

សព្វថ្ងៃនេះ ពាក្យខ្មែរច្រើនណាស់ប្រើអក្សរ «ណ» ក្នុងអក្ខរាវិរុទ្ធរបស់ខ្លួន។ ឧ. (១) កណ្ដាល កណ្ដឹង ដណ្ដឹង ដណ្ដើម បណ្ដែត បណ្ដោយ សណ្ដូក សណ្ដែក ...។ ឧ. (២) កំណើត កំណាយ ចំណាំ ចំណត ដំណួច(ដួច) ដំណៀល(ដៀល) តំណួច(តួច) តំណិះ(តិះ) បំណាំ បំណែក សំណង អំណោយ ...។

១.ក្នុងវេយ្យាករណ៍បាលី «ព្យញ្ជនៈទី៥នៃវគ្គនីមួយៗ អាចតម្រួតលើព្យញ្ជនៈទាំង៤តួក្នុងវគ្គ»។ ដូចនេះ ព្យញ្ជនៈចុងវគ្គ «ណ» អាចតម្រួតលើតួ «ដ» បានដោយឥតទើសទាស់។ បានសេចក្ដីថា ឧ. (១) ខាងលើគោរពតាមវេយ្យាករណ៍បាលីយ៉ាងត្រឹមត្រូវ។

២.ក្នុងសិលាចារឹកមានពាក្យខ្លះសរសេរបែបខាងក្រោមនេះ ៖

កន្ទាល -- 1 (សិលាចារឹក តាកែវ)
ចំនត-- (សិលាចារឹកបាសែត បាត់ដំបង)
ចំនាំ (សិលាចារឹក វត្តឯក)
ចំនោម-- (សិលាចារឹក គុហាលួង)
ចំន្យរ > 2 ចំនិរ-- (សិលាចារឹក បន្ទាយឆ្មារ)
បំនោស (សិលាចារឹក គុហាលួង)(=ធ្វើឲ្យបួស)
បិន្ទ (សិលាចារឹក កម្រៀង) =បិណ្ឌ
រត្នគន (សិលាចារឹក កម្រៀង) =រត្នគណ
ចន្ទ្រគន (សិលាចារឹក កម្រៀង) =ចន្ទ្រគណ
ជ្វាធរគន (សិលាចារឹក កម្រៀង) =ជ្វាធរគណ
វិគេមគន (សិលាចារឹក កម្រៀង) =វិសេសគណ
គន (សិលាចារឹក អង្គខ្វារ) =គណ
ប្រមថគន (សិលាចារឹក វត្តខ្មោត) =ប្រមថគណ
វិស្នុ: (សិលាចារឹក ភូមិជ្រៃ) =វិស្ណុ

ដូចនេះ ខ្មែរបុរាណពុំគោរពវេយ្យាករណ៍បាលីទេ។

-ខ្មែរបុរាណពុំប្រើតួ «ណ» ក្នុងការសរសេរពាក្យខ្មែរសុទ្ធទេ។

-ខ្មែរបុរាណបានធ្វើខេមរនីយកម្មពាក្យបាលីសំស្ក្រឹតខ្លះ។

-ខ្មែរបុរាណប្រើតួ«ន» ក្នុងអក្ខរាវិរុទ្ធខ្មែរ។

៣. ក្នុងបណ្ដាញាតិសព្ទខ្មែរ ៖

កើត ខ្នើត កំណើត
កាយ ខ្នាយ កំណាយ

1.សញ្ញានេះ«--»ឈ្មោះវិរាមៈសម្រាប់បំបាត់ស្រៈចេញពីតួព្យ.ប្រកប

2. បុរាណ «ឫ» = ិ (ស្រៈកន្លះយ [j] = [i] អិ

កោស ខ្នោស កំណោស
ចុក ឆ្នុក ចំណុក
បែក ផ្នែក បំណែក
សង ស្នង សំណង

ពាក្យជួរខាងចុង ដូចជា កំណើត កំណាយ កំណោស ចំណុក ... គួរសរសេរ ជា កំនើត កំនាយ កំនោស ចំនុក ចំនាំ បំនែក សំនង បែបនេះវិញ ព្រោះពាក្យទាំងនោះ ជាក្រុមញាតិនឹងពាក្យ ខ្នើត ខ្នាយ ឆ្នុក ឆ្នាំ ផ្នែក ស្នង ដែលសុទ្ធតែមានអន្តរាបទ «ន» ( ្ន ) ចុះបន្ថែមជាមួយ។

៤.ក្នុងវេយ្យាករណ៍ខ្មែរពុំមានបំរាមចំពោះការសរសេរដូចជា កំនក ចំនុច សំនង... បែបនេះឡើយ។ ពាក្យទាំងនេះពុំអាចអានជា ៖

កំ--នក ចំ--នុច សំ--នង ដូចនេះបានទេ ពីព្រោះ«ន» ត្រូវក្លាយជា « ន៎ = ណ» ក្នុងករណីដែលមានព្យាង្គដើម គឺជាពួកខ្យល់ «អ» (ក្បួនមូសិកទន្ត « ៉ »)។

៥. ក្នុងសម័យបុរាណ វគ្គទី៣ (វគ្គ «ដ») ប្រើសម្រាប់សរសេរតែពាក្យបាលីសំស្ក្រឹតហើយពុំប្រើក្នុងអក្ខរាវិរុទ្ធខ្មែរសុទ្ធទេ។ ហេតុនេះហើយ បានជាខ្មែរបុរាណប្រើ «ត» ជំនួស «ដ»។ ឧ.

តេល (ដែល) ត (ដ៏)
តប (ដប់) តិង (ដឹង)
តុត (ដុត) តាក (ដាក់)
តោង (ដូង) តោយ (ដោយ)...។ ដូចនេះ ៖

១.តាមយោបល់ខ្ញុំ គួរកុំប្រើអក្សរ«ណ» ក្នុងអក្ខរាវិរុទ្ធខ្មែរ។

២.ឬប្រើតែចំពោះពាក្យបាលីសំស្ក្រឹតក្លាយ។

៣.ឬក៏ប្រើតែចំពោះពាក្យណាដែលទាក់ទងនឹងវគ្គទី៣។ ក្រៅអំពីនោះប្រើព្យញ្ជនៈ«ន»ទាំងអស់។

ឧ. បណ្ដាច់ (ប+ដាច់) បណ្ដឹង (ប+ដឹង)
ដំណួច (ដួច) ដំណើរ (ដើរ)
តែ តំនួច (តួច) កំនើត (កើត)
តំនាង (តាង) អំនោយ (ឱ្យ)... សមយ៕

**សង្គមខ្មែរតាមរយៈតំណាលកថាប្រជាប្រិយ ២០២២**
**បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង**

# ២- ស្វែងយល់ពី សីលធម៌សង្គមជាតិ

លោកអ្នកបានតាមដានពិនិត្យ មនុស្សដែលមានសម្បជញ្ញៈ ចេះត្រិះរិះពិចារណា ដឹងល្អ ដឹងអាក្រក់ ស្គាល់ខុស ស្គាល់ត្រូវ តាមសំណេរនៅលើទំព័រខាងដើមរួចហើយ។ យើងគួរពិចារណាថា ហេតុអ្វីបានជាបុព្វបុរសនាំគ្នា ចងក្រងក្រមសីលធម៌ (បទដ្ឋាន) ដើម្បីប្រតិបត្តិតាមជារៀងរហូតមក។ មិនតែប៉ុណ្ណោះ ក្រោយមក ក្បួនខ្នាតសីលធម៌ដដែលនោះត្រូវបានបញ្ចូលជាបទបញ្ញត្តិសីលធម៌របស់សាសនាថែមទៀត ហើយត្រូវបានសរសេរជាលាយលក្ខណ៍អក្សរលើថ្មដា លើស្លឹករឹត ឬលើក្រដាស នៅពេលក្រោយៗមកទៀត។ តើមនុស្សប្រាថ្នាចង់បានអ្វី? ចម្លើយ គឺមនុស្សជាតិប្រាថ្នាចង់បានសេចក្ដីសុខចម្រើន សំបូរសប្បាយ និងចាកផុតពីគ្រោះភយន្តរាយ មានរបៀបរបបក្នុងការរស់នៅក្នុងសង្គមមួយ។ សីលធម៌សង្គមមនុស្សជំនាន់ដើម លេចចេញជារូបរាងជាមួយនិងគតិធម៌ទ្រទ្រង់មនុស្សជាតិ ឬតម្លៃមូលដ្ឋាន។តម្លៃនេះសាបសូន្យកាលណាមនុស្សនិងសម្បជញ្ញៈរបស់មនុស្ស ត្រូវរលត់រលាយទៅជាមួយគ្នា។ សំនួរតែមួយគត់ចោទសួរថា៖ តើអ្វីទៅហៅថា គតិធម៌ ឬតម្លៃមូលដ្ឋាន ដែលមនុស្សបានរកឃើញហើយបញ្ជូនបន្តៗគ្នា តាំងពីមនុស្សចេញផុតពីហ្វូងសត្វស្វាមនុស្ស «ព្រីម៉ាត» ហើយសង្គមមនុស្ស បានចេះគោរពថែរក្សាទុកមកដល់យើងរាល់គ្នាសព្វថ្ងៃ? តើតម្លៃនោះមានអ្វីខ្លះទៅ? (ពាក្យថាតម្លៃ បកប្រែតាមន័យពាក្យបារាំង គឺអ្វីៗដែលពិត សោភ័ណល្អ កំណត់តាមការវិនិច្ឆ័យមួយ ស្របទៅនឹងការវិនិច្ឆ័យរបស់សង្គម-ពេលវេលា។ តម្លៃសីលធម៌ - សង្គម - សិល្បវិទ្យា ) ចម្លើយបានបញ្ជាក់ថា តម្លៃនោះមានចំនួនប្រាំ ប្រសិនបើតម្លៃណាមួយមិនមាននៅក្នុងសង្គមមនុស្សនោះទេ មនុស្សជាតិនឹងត្រូវតែរលាយសាបសូន្យ។

ជាការពិតហើយ សីលធម៌កើតមកមិនដូចគ្នាទេគឺប្រែប្រួលឬរទៅតាមតំបន់ទៅតាមសម័យកាលទៅតាមស្ថានការណ៍។ តែគតិធម៌មូលដ្ឋានទាំងប្រាំត្រូវនៅជាចន្ទល់ ជាសសរទ្រមនុស្សជាតិ កុំឱ្យរលត់រលាយ ត្រឡប់ទៅជាសារធាតុដើមវិញ។ គតិធម៌នេះ សង្គមមនុស្សកំណត់ថា ជាតម្លៃមូលដ្ឋាន ឬគតិធម៌ទ្រទ្រង់មនុស្សជាតិ ។

១. សេរីភាព ( La liberté )

សេរីភាព ចាត់ទុកជាគតិធម៌ទីមួយរបស់មនុស្ស ព្រោះមនុស្សមានការសម្រេចធ្វើ ឬមិនធ្វើអំពើអ្វីមួយ តាមបញ្ជាសម្បជញ្ញៈប្រាប់ថា ល្អ ឬអាក្រក់ ខុសគ្នាពីសត្វ។ អ្នកប្រព្រឹត្តអំពើទទួលការខុសត្រូវតែម្នាក់ឯងគត់។ សេរីភាព មិនមែនជាការលុបបំបាត់កាតព្វកិច្ចរបស់មនុស្សទេ ។ វាជាសិទ្ធិ ឬអំណាចរបស់មនុស្ស សម្រាប់សម្រេច ឬមិនសម្រេចបំពេញកាតព្វកិច្ចតែប៉ុណ្ណោះ ( faculté de choisir ou non de remplir les obligations )។

សេរីភាពក្នុងក្របខណ្ឌសីលធម៌ មិនមែនជាសិទ្ធិដើម្បីធ្វើអ្វីបានទៅតាមចំណង់របស់មនុស្សម្នាក់ៗទេ ។ ប្រសិនបើសេរីភាពធ្វើអ្វីបានទាំងអស់នោះ គឺវានឹងនាំទៅរកអយុត្តិធម៌ ទៅរកការវិនាស បាត់បង់សេរីភាព។ មនុស្សត្រឡប់ទៅរកភាពដើមវិញ គឺសត្វតិរច្ឆាន។ ទង្វើអ្វីតាមទំនើងចិត្ត ប៉ះពាល់សិទ្ធិសេរីភាពអ្នកដទៃនោះ ជាការមិនគោរពសីលធម៌ មិនគោរពច្បាប់សម្រាប់រដ្ឋ។ រវាងអ្នកមានអំណាច និងអ្នកទន់ខ្សោយ សេរីភាពអ្នកខ្លាំងតែងតែសង្កត់សង្កិនអ្នកទន់ខ្សោយ។ ចំពោះបញ្ហានេះ ឧទាហរណ៍មានច្រើនណាស់ នៅលើពិភពលោកយើងនេះ ជាពិសេស ខាងផ្នែកសាសនានិងខាងផ្នែកនយោបាយគឺការគ្រប់គ្រងប្រទេស។

សូក្រាតស្លាប់ដោយផឹកថ្នាំពុល តើបណ្ដាលមកពីមូលហេតុអ្វី? គឺអំណាចគ្រប់គ្រងរដ្ឋក្រិចជំនាន់នោះ បានចោទប្រកាន់គាត់ថា មិនគោរពអាទិទេព និងធ្វើឱ្យយុវវ័យខូចអនាគត ដោយសារតែការយល់ឃើញរបស់គាត់។

កាលីលេ ( Galilée ) តារាវិទូ ដោយមកពីការគាបសង្កត់ខ្លាំង បានសុំដកពាក្យសំដីដែលគាត់បានពោលមកហើយថា « ផែនដីវិល » នៅចំពោះមុខតុលាការ ( Inquisition ) របស់សាសនាគ្រិស្ត នាឆ្នាំ

១៦៣៣។

ដោយហេតុមកពីការប្រើសេរីភាព សង្កត់សង្កិនបែបនេះហើយទើបសង្គ្រាមបង្ហូរឈាមនៅក្នុងប្រទេសជាច្រើន បានទាមទារសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋ។ សេចក្តីថ្លែងការណ៍ ស្តីពីសិទ្ធិមនុស្ស និងពលរដ្ឋ(១៧៨៩)និងសេចក្តីថ្លែងការណ៍សាកលស្តីពិសិទ្ធិមនុស្ស (១៩៤៨) ជាសក្ខីភាពនៃការតស៊ូប្រយុទ្ធដើម្បីសេរីភាព ។

ចំពោះសេរីភាពដាច់បង្ហៀរ តើមានធម៌អ្វីមកទប់បានឬទេ ដើម្បីញ៉ាំងឱ្យមនុស្សជាតិមានដំណើរទៅរកអរិយធម៌ និងវឌ្ឍនធម៌បន្ថែមទៀត ?

តាមព្រះពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្តែងអំពីព្រហ្មវិហារធម៌ដើម្បីទុកជាគន្លងនៃការប្រតិបត្តិត្រឹមត្រូវរបស់សត្វលោក។ ធម៌ជាលំនៅនៃចិត្តដ៏ប្រសើរ មានបួនយ៉ាងគឺ ៖

1. មេត្តា : សេចក្តីស្រឡាញ់រាប់អានសព្វសត្វ គឺចង់ឱ្យគេបានសុខ

2. ករុណា : សេចក្តីអាណិតសព្វសត្វ គឺជួយគេឱ្យផុតពីសេចក្តីទុក្ខ

3. មុទិតា : សេចក្តីត្រេកអរ សប្បាយរីករាយចំពោះសព្វសត្វ នៅពេលគេបានសេចក្តីសុខ

4. ឧបេក្ខា : សេចក្តីតាំងចិត្តជាកណ្តាល ទៅរកសព្វសត្វ

២. សមធម៌ ឬ គតិយុត្តិធម៌ ( L' Equité )

ដើម្បីរក្សាសេរីភាពឱ្យនៅជាគតិធម៌ចម្បងទីមួយមនុស្សត្រូវតែគោរពគតិធម៌ទីពីរនេះគឺមិនត្រូវប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួន ឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាព ត្រូវប្រព្រឹត្តតាមគតិយុត្តិធម៌ គឺតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។

ក្នុងការអប់រំ ដើម្បីធានាបានសមធម៌ រដ្ឋត្រូវតែមានវិធានការ រៀបចំរចនាសម្ពន្ធសិក្សាយ៉ាងណាដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូប មានភព្វសំណាងបានរៀនសូត្រគ្រប់គ្នា ( égalité des chances devant l' education ) អ្នករាជការត្រូវតែបានបៀវត្សស្របទៅតាមគុណសម្បត្តិ«សមត្ថភាព» (Mérite égal ; salaire égal ) ។

៣.សច្ចធម៌ ( La Vérité )

កាលណានិយាយពីគតិយុត្តិធម៌ គឺនិយាយពីសច្ចធម៌។តើធ្វើដូចម្តេចនឹងអាចកាត់ឱ្យបានស្របតាមគតិយុត្តិធម៌រវាងសេរីភាពពីរប្រឆាំងគ្នាប្រសិនបើមិនស្គាល់ ឬ មិនដឹងតថភាពនៃស្ថានការណ៍ឱ្យបានច្បាស់លាស់ ។

ដើម្បីអាចកាត់សេចក្តីឱ្យស្របតាមសមធម៌ អាជ្ញាកណ្តាលត្រូវតែដឹងឱ្យ បានសព្វគ្រប់នូវការពិតចៀសវាងការលំអៀងទៅតាមអគតិទាំងបួន មោហា-គតិ ឆន្ទាគតិ ទោសាគតិ ភយាគតិ។ សច្ចធម៌ដូចគ្នានឹងសមធម៌ជាធម៌ស្រោចស្រង់ការពារសេរីភាពកុំឱ្យសាបសូន្យ។ ដើម្បីជាគំនិតពិចារណា សូមលើកដោយសង្ខេបរឿងស្ត្រីពីរនាក់ដណ្តើមកូនគ្នាដូចតទៅនេះ ៖ មាននិទានថា ស្ត្រីពីរនាក់មានកូនដូចគ្នា ម្នាក់កូនស្លាប់ម្នាក់ទៀតកូននៅរស់។នាងមានកូននៅរស់បានពកូនទៅផ្ងូតទឹក ហើយក៏បានជួបនឹងនាងដែលមានកូនស្លាប់នៅកណ្តាលផ្លូវ។ នាងដែលមានកូនស្លាប់និយាយថា ៖

-នាងអើយ ! កូននាងក៏ដូចកូនខ្ញុំម្ល៉េះ ឱ្យខ្ញុំសុំថើបកូននាងបន្តិចមក បានថើប និងបំបៅដោះកូនរួចនាងនោះក៏ពកូនដើរទៅកាន់លំនៅរបស់ខ្លួន។ ស្ត្រីជាម្តាយស្រែកហៅកូន ទាមទារយកមកវិញ។ ស្ត្រីនោះឆ្លើយថា ៖

-កូនអញទេតើ ម្តេចហាងថាកូនឯង ?

ស្ត្រីទាំងពីរនាក់នោះឈ្លោះប្រកែកដណ្តើមកូនគ្នាទៅវិញទៅមកមិនដាច់ស្រេចសោះក៏នាំគ្នាទៅប្តឹងចៅក្រម។

ចៅក្រមជំនុំពិចារណាអស់បីរាត្រី កាត់សេចក្តីមិនដាច់ស្រេចមិនយល់ប្រាកដថាជាកូននាងណាមួយឡើយ ទើបនាំស្ត្រីទាំងពីរនាក់និងកូន ចូលគាល់ក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រតាមដំណើររឿង។

ព្រះមហាក្សត្រទ្រង់ ជ្រាបដំណើររឿងសព្វគ្រប់ហើយទើបព្រះអង្គទ្រង់ព្រះចិន្តាពិចារណាដោយព្រះប្រាជ្ញា រួចទ្រង់ត្រាស់បង្គាប់ឱ្យយកកូននោះទៅដាក់កណ្តាលទីរួចឱ្យស្ត្រីទាំងពីរនាក់នោះដណ្តើមគ្នា «បើអ្នកណាដណ្តើមយកបាន ឱ្យអ្នកនោះយកកូន

នោះចុះ»។ ព្រះឯងដូច្នោះហើយ ស្ត្រីទាំងពីរក៏ចូលទៅដណ្ដើមគ្នា។ស្ត្រីកូនស្លាប់ក៏ស្ទុះទៅចាប់យួរយកកូននោះភ្លាម ពុំគិតពិចារណាថា បាក់បែករហែកដៃជើងឡើយ។ ឯស្ត្រីជាម្ដាយ ខឹងនឹងមេនោះណាស់ តែមានចិត្តអាណិតអាសូរកូនខ្លួនក្រៃពេក ក៏ដើរចូលទៅថ្នាក់ថ្នមអោបក្រសោបយកកូនដោយបក់ព្រលឹងលុះឃើញស្ត្រីនោះខំពុះពារប្រវាចាប់កូន ពុំគិតបាក់បែកឆ្អឹងឆ្អែងយ៉ាងនោះ ក៏លែងកូនពីដៃឱ្យកូនបានទៅដៃស្ត្រីនោះទៅ។ ព្រះមហាក្សត្រមានព្រះបន្ទូលថា៖

-នាងដែលលែងកូនឱ្យបានទៅគេនោះ ជាម្ដាយពិតៗ ព្រោះត្បិតមានចិត្តអាសូរករុណាកូន រីឯស្ត្រីដែលដណ្ដើមកូនបានទៅនោះពុំមែនជាម្ដាយពិតរបស់កូននោះទេព្រោះឥតមានចិត្តអាណិតអាសូរកូនបន្តិចសោះ ខំដណ្ដើមយកតែឈ្នះដៃ។

ទ្រង់មានព្រះបន្ទូលដូច្នោះហើយ ក៏ទ្រង់កាត់សេចក្ដីឱ្យកូននោះបានទៅស្ត្រីជាម្ដាយវិញ។ចំពោះស្ត្រីដែលដណ្ដើមឆក់យួរយកកូននោះ ព្រះអង្គទ្រង់បញ្ជាឱ្យផ្ដន្ទាទោស ផ្ចាញ់ផ្ចាលឱ្យរាងចាលហោង។ (ដកស្រង់ចេញពីសៀវភៅរឿងព្រេងខ្មែរ ភាគទី៣ បោះផ្សាយដោយពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៧១)។

ចំពោះគតិធម៌វិញ តើស្ត្រីទាំងពីរនាក់នេះ ប្រើសិទ្ធិសេរីភាពរបស់ខ្លួនបែបណា? នាងទី១ (កូនស្លាប់) ប្រើសិទ្ធិរំលោភលើនាងទី២(កូនរស់)។ សិទ្ធិសេរីភាពទាំងពីរប្រើខុសគ្នាមួយរំលោភបំពានទៅលើកម្មសិទ្ធិ(កូន)របស់ម្នាក់ទៀត។ នាងទី២ ប្រើសិទ្ធិសេរីភាពប្រឆាំងវិញ តែស្របនឹងសីធម៌ ។ សេរីភាពនិងសេរីភាព ប្រឈមដាក់គ្នា បង្កើតបានជាជម្លោះវាយតប់គ្នាបែកមុខបែកមាត់។ ដើម្បីដោះស្រាយជម្លោះនេះ ស្ត្រីទាំងពីរត្រូវតែរត់ទៅរកចៅក្រម ដើម្បីឱ្យជំនុំជម្រះកាត់សេចក្ដី។ ចៅក្រមមិនមានប្រាជ្ញាត្រិះរិះពិចារណាវែងឆ្ងាយ កាត់សេចក្ដីមិនដាច់ស្រេចរកយុត្តិធម៌មិនឃើញ។ ព្រះមហាក្សត្រប្រកបដោយព្រះប្រាជ្ញាបានកាត់រឿងជម្លោះនេះដោយគតិយុត្តិធម៌ (L'équité ou la justice)។ដើម្បីរកឱ្យស្របទៅតាមគតិធម៌ ព្រះអង្គទ្រង់ចាត់ឱ្យធ្វើពិសោធន៍ ដើម្បីរកឱ្យឃើញសច្ចធម៌ (La vérité)។ តើសច្ចធម៌ លេចចេញឱ្យឃើញនៅត្រង់ណា? គឺនៅត្រង់ម្ដាយពិតប្រាកដមិនហ៊ានធ្វើបាបកូន ព្រោះអាណិតកូន។

ដូចនេះ យើងឃើញថា គតិធម៌ សេរីភាពត្រូវតែមាន គតិធម៌ យុត្តិធម៌ និងសច្ចធម៌ ទប់កុំឱ្យប្រើហួសព្រំដែន រំលោភបំពានទៅសេរីភាពអ្នកដទៃ។ ខ្វះសីលធម៌ គឺខ្វះភពថ្លៃថ្នូរ។

៤. ជីវកាតព្វកិច្ច (L'obligation biologique)

យើងគួរពិចារណាថា ប្រសិនបើមនុស្សស្លាប់បាត់បង់ជីវិតអស់ទៅ គោលការណ៍សេរីភាព សមធម៌ និងសច្ចធម៌ ក៏ត្រូវរលត់សាបសូន្យទៅដែរ។ បញ្ហាទាំងឡាយដែលក្រមសីលធម៌បានលើកឡើងតម្រូវឱ្យមនុស្សបំពេញលក្ខខណ្ឌផ្ទាល់របស់ខ្លួន ក្នុងការធានារ៉ាប់រងឱ្យមនុស្សជាតិ មានជីវិតរស់នៅជាមនុស្ស ប្រកបដោយសីលធម៌ ជាមនុស្សមានសេរីភាព។ ប្រសិនបើមនុស្សមិនសម្រេចចិត្តចង់បន្តពូជពង្សរបស់ខ្លួនឬមួយមិនព្រមថែរក្សាកូនចៅដែលកើតមកហើយ ឱ្យវាធំធាត់ មានសុខភាពល្អ សម្រាប់បន្តទៅជំនាន់ក្រោយទៀតទេ នោះមនុស្សជាតិនឹងសាបសូន្យ ដោយខ្វះសម្បជញ្ញៈ។

សង្គមមនុស្សនាបច្ចុប្បន្នកាលបានជ្រួតជ្រាបហើយពីបញ្ហានេះ។ រដ្ឋអំណាចបានរិះរកគ្រប់មធ្យោបាយ លើកទឹកចិត្តឱ្យបុរសស្ត្រីបង្កើតគ្រួសារ ដោយតម្រូវឱ្យមានក្រសួងសុខាភិបាល ផ្នែកគាំពារមាតា និងទារកនិងក្រសួងសង្គមកិច្ចផ្នែកទទួលធានារ៉ាប់រងនិវត្តជនជាដើម។ប្រទេសឧស្សាហកម្មធំៗមានកង្វល់ពីតុល្យភាពប្រជាជន ។ សម្បជញ្ញៈមនុស្ស ក៏ដូចជាសេរីភាពដែរ ដើម្បីឱ្យសមស្របតាមគតិបណ្ឌិត ត្រូវបានបង្ខំឱ្យបំពេញជាបឋមនូវជីវកាតព្វកិច្ច គឺកាតព្វកិច្ចបន្តពូជមនុស្ស ឱ្យបានស្ថិតស្ថេរយូរអង្វែងទៅហើយប្រកបដោយមនុស្សធម៌។

៥. កាតព្វកិច្ចសង្គម-វប្បធម៌ (L'obligation socio-culturelle)

ក្រៅពីជីវកាតព្វកិច្ច មនុស្សត្រូវបំពេញកាតព្វកិច្ចមួយទៀត គឺកាតព្វកិច្ចបញ្ជូនបន្តនូវសមិទ្ធផលសង្គមវប្បធម៌ឱ្យទៅមនុស្សជំនាន់ក្រោយ។ បុព្វបុរសជំនាន់មុន បានទុកកេរដំណែលជាច្រើន។ យើងទាំងអស់គ្នាជាកូនចៅ ជាប់ជំពាក់បំណុល ដែលមិនអាចសងគាត់វិញបាន ទាំងបំណុលផ្នែកសម្ភារៈ និងផ្នែក

វប្បធម៌។ ដើម្បីតបស្នងសងគុណគាត់វិញ ឬរំដោះបំណុលទាំងនោះ យើងមានតែមធ្យោបាយពីរ គឺទីមួយជួយបង្ហាត់បង្រៀនអ្នកនៅជុំវិញនូវចំណេះដឹងរបស់ខ្លួនទាំងខាងបញ្ញានិងទាំងខាងសីលធម៌។ទីពីរខិតខំបំពេញការងារ ដើម្បីទុកកេរបន្តទៅទៀត។ ឧទាហរណ៍ៈ ដាំដើមឈើ កសាងផ្លូវថ្នល់ សង់សាលារៀន...ឬបង្កើតស្នាដៃសិល្បៈ ទុកជាកេរដំណែលដល់កុលបុត្រ កុលធីតាជំនាន់ក្រោយ។ មនុស្សពេញវ័យជំនាន់បច្ចុប្បន្ន ត្រូវមានសម្បជញ្ញៈ ដឹងថាខ្លួនជាអ្នកទទួលបេសកកម្មបញ្ជូនបន្តនូវកេរដំណែលអ្វីមួយ។

នេះជាសន្និសញ្ញាមូលដ្ឋានរវាងបុគ្គលមួយរូប និងមនុស្សជាតិ ឬសង្គមមនុស្ស។ បើមិនដូច្នោះទេ សង្គមមនុស្ស មិនមានការរីកចម្រើនឡើយ។ ហើយយូរៗទៅនឹងរៀវរួញបន្តិចម្តងៗ រហូតដល់ការសាបសូន្យ។ ម្យ៉ាងវិញទៀត កាតព្វកិច្ចសង្គម-វប្បធម៌ នាំបំផុសគំនិតច្នៃប្រឌិត កែលម្អវត្ថុដែលមានមករួចហើយ ឱ្យមានសោភ័ណភាពឡើងទៅទៀត។ នេះជាការបំពេញកាតព្វកិច្ចមួយដែរ។បុរេប្រវត្តិបានបង្ហាញយើងគ្រប់គ្នា ឱ្យដឹងនូវការវិវឌ្ឍន៍នៃសង្គមមនុស្សជំនាន់ដើម ដែលបានធ្វើប្រដាប់ប្រដាប្រើប្រាស់មុនដំបូងបង្អស់ពីថ្មបំបែក។ បន្តក្រោយមក ពីថ្មសំលៀង ពីលង្ហិន ពីដែក ។ គេបានរកឃើញភ្លើងសម្រាប់ចម្អិនអាហារ ដោយក្លូតឬស្សី ឬឈើ និងដោយវាយថ្មឱ្យចេញផ្កាភ្លើង។ ប្រសិនបើមនុស្សមិនមានគំនិតរិះរកពិសោធន៍ទេនោះ មនុស្សជំនាន់ក្រោយៗមក នៅតែដូចដើមដដែលៗគឺមិនមានការប្រែប្រួលឈានឡើងឡើយ។វប្បធម៌រីកចម្រើននិងវិទ្យាសាស្ត្រ-បច្ចេកទេសលូតលាស់ ក៏ដោយសារអ្នកស្រាវជ្រាវ។

បុព្វបុរសកម្ពុជា បានកសាងប្រាសាទសិលាមានក្បាច់រចនារស់រវើកដែលជាស្នាដៃស្ថាបត្យកម្មគួរស្ញប់ស្ញែង និងបានស្ថាបនាប្រព័ន្ធប្រឡាយទឹកទុកជាកេរដំណែល។ តើខ្មែរបច្ចុប្បន្នបានអ្វីតបស្នងសងគុណ បើនៅតែប្រទូស្តរ៉ាយគ្នាមិនចេះចប់ និងភ្លេចអស់គុណបុព្វបុរស។ដើម្បីធ្វើការប្រៀបធៀបតម្លៃជាមូលដ្ឋានទាំងប្រាំ និងការចាត់តាំងគ្រប់គ្រងប្រទេសកាលពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៨ស្នេរសូមលោកអ្នកក្រឡេកមើលទៅក្រោយនូវស្ថានភាពប្រទេសកម្ពុជាក្នុងពេលត្រួតត្រារបស់បនប្រល័យពូជសាសន៍។ តើគតិធម៌ជាមូលដ្ឋានទាំងប្រាំ ត្រូវបានយកមកអនុវត្តឬទេ ? ចម្លើយ ! មិនមានទាល់តែសោះ គេបណ្តេញប្រជាជនចេញពីផ្ទះរបស់ខ្លួន ឱ្យដើរដោយមុខក្រៀមក្រំ ស្រងូតស្រងាត់ មិនដឹងទៅកន្លែងណា។ ខ្លះយំខ្លះស្លាប់ចោលកូនចៅ ចោលឆ្អឹងនៅភូមិស្រុកគេ ខ្លះកើតកូននៅកណ្តាលវាលស្រែ ក្រោមដើមឈើ ។ ក្នុងការរស់នៅក្នុងសហករណ៍ គេទុកមនុស្សជាសត្វសេរីភាពនិយាយត៉វាអ្វី ត្រូវបំបិទ គឺត្រូវធ្វើគ ធ្វើថ្លង់។ នរណាមួយហ៊ាន«ខ្ញើក» អ្នកនោះត្រូវបាត់ខ្លួន។ គេបំផ្លាញមនោសញ្ចេតនាគ្រួសារ កាត់ផ្តាច់ចំណងទាក់ទងគ្រួសារ ដោយបញ្ជូនទៅធ្វើការដាច់ដោយឡែកៗពីគ្នា ឆ្ងាយពីគ្នា មិនមានពេលណាជួបមុខប្រពន្ធកូនឡើយ ។រចនាសម្ពន្ធសង្គមនិងវប្បធម៌ត្រូវបានបំផ្លាញខ្ទេចខ្ទី។ បើគ្រប់គ្រងរដ្ឋតាមតាមរបៀបប្រល័យពូជសាសន៍បែបនេះ សង្គមជាតិខ្មែរត្រូវតែសាបសូន្យផុតពូជ។

**ក្រុមសីធម៌សង្គម - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង**

## ១- វប្បធម៌ជាតិស្រុកខ្មែរ ( ពាក្យ ៧ )

មើលមៀនជ្រៃជ្រេសង្កែថ្វាន់
គ្រៀលត្រស់ក្រវ៉ាន់គុយស្រគំ
ស្រឡីស្រឡៅក្របៅក្ទម្ព
ទ្រនំអាអូដ្ឋចង្អូរត្នាត។
ដង្កោទ្រយឹងខ្ទឹងក្រសាំង
អម្ពិលភ្លូងភ្លាំងទាំងភ្លូបាត
គូលែនទុរេនមៀនលាំងសាត
មាត់បាតបង្គោញ្ញៅចាន់ចារ។
ត្របែកត្រសេកអំបែងថ្ងៃ
អង្រ្កងស្មាច់ស្មៃរោគរកា
ក្រូចក្រាយស្វាតស្វាយត្រាចគ្រៀលស្វា
សេដាសណ្ដាន់ថ្វាន់ជ្រៃជ្រៃ។
មានទាំងដកពាយវាយដកព
សង្ឃ័រពង្រពាក់វាំងស្មី
ភ្នំភ្នែងផ្លែស្រែងលោតលាំងដៃ
សន្ទែក្រខុបងប់ក្រឡាញ់។
ច្រមាសបុស្សនាគច្រកែងទូយ
ប្រផេញគោមួយឈើទាលត្រាញ់
រាជឆ្លឹសធ្មេញត្រីរៃអញ្ចាញ
អង្កាញ់អង្កោលកណ្ដោលបាត។
ត្រាចគ្រៀកចង្រៀកច្រេសខ្ទឹងក្ទម្ព
គគីរលាំងភ្នំបេងបាយម៉ាត
ស្ដុកស្ដុរស្ដីស្ដៅត្រាវក្ដួចក្ដាត
លាំងសាតសត្បារកាស្រល់។ ...

ទុំទាវ - ព្រះបទុមត្ថេរ សោម

## ២- កុំភ្លេចខ្លួន !

| | | |
|---|---|---|
| កុំដៀលអ្នកស្រែ | ត្រកូលឯងខ្មែរ | កុំប្រែក្រឡាស់ |
| ក្រឡេកឃើញគុណ | ទន់ខ្លួនសំពះ | កុំធ្វើអ្នកណាស់ |
| | កុំភ្នះអ្នកក្រ។ | |
| អ្នកកុំភ្លេចគុណ | គ្រូលេខនព្វន្ត | គ្រូសូត្រអក្សរ |
| កុំចាប់ដៃទាញ | គំនាប់ងក់ង | កុំជដៃកត |
| | ស្មើមិត្តសម្លាញ់។ | |
| វាស្រ្តរត់ជូលជ្រក | កុំថាគេថោក | កុំអើឯងអញ |
| ពាក្យពុំពីរោះ | គេកើតមួក្នាញ់ | គេដៀលផ្ងាលផ្ងាញ់ |
| | អន្តរាយកេរ្តិ៍ឈ្មោះ។ | |
| កុំឆ្មើងអាងបុណ្យ | ស្រដីឱ្យទន់ | ពោលពាក្យពីរោះ |
| ខ្លួនអ្នកនឹងថ្កើង | នឹងឡើងសក្តិយស | កុំឆ្លៀតនាំឈ្លោះ |
| | ញុះញង់អ្នកធំ។ | |

ច្បប់ក្រមង៉ុយ - ព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ

## ករុម្រខនខកថា : ជាតិនេះស្មាលា !

អ្នកគ្រូ ល.យ.ស. មានលក្ខណៈប្លែកពីគេឯង មានអាយុ២៨ឆ្នាំ រូបរាងល្អលើសបង្គួរ ឫកពាស្រគត់ស្រគំ ចូលចិត្តសិក្សាស្រាវជ្រាវ មាននិស្ស័យជាមួយសិស្សនិងបុគ្គលិករួមសាលា អ្នកគ្រូមិនព្រមយកគ្រួសារតាំងពីចេញធ្វើការមក ។នេះមិនគិតកាលនៅកំពុងរៀនច្បាប់គ្រូ ដែលមានអស់លោក ឬកូនអស់លោកមកដណ្តឹងមិនដឹងប៉ុន្មាននោះផង។ខ្ញុំបានស្គាល់គេជិតស្និទ្ធ ជិតមួយឆ្នាំមកហើយ ដោយសាររៀនមហាវិទ្យាល័យនិងថ្នាក់ជាមួយគ្នាផង រៀនជាក្រុមជាមួយគ្នាផងចិត្តគំនិតនិងសំដីសំដៅមិនសូវខុសគ្នាផង ។ យើងទៅមករកគ្នាពុំសូវលោះពេល ។ ល្ងាចថ្ងៃសៅរ៍មួយ ដើម្បីអស់ឆ្ងល់ ខ្ញុំដាច់ចិត្តទៅរកគេ។

ក្រោយពីញញឹមរាក់ទាក់ តែទឹកកក និងប្រាជ្ញព្រោកនេះនោះនាយអាយបន្តិចមក ខ្ញុំក៏ចូលសាច់រឿង ៖

-ខ្ញុំចង់ដឹងរឿងមួយ...បើម៉េចៗកុំប្រកាន់ណ៎ា

-រឿងអី ? ... និយាយទៅ (គេសើចញឹមៗ ... គួរឱ្យស្រឡាញ់)

-ខ្ញុំឮគេថា យើងហ្នឹងស្អប់ប្រុសៗខ្លាំងណាស់ មិនរវីរវល់ទេរឿងគ្រួសារ... អាចប្រាប់ខ្ញុំបានទេ ហេតុអី... ?

-គេសើចញឹមៗ ទឹកមុខធម្មតា ហាក់គ្មានភ្ញាក់ផ្អើលបន្តិចសោះ រួចក៏តបមកវិញថា ៖

-អ៊ូហូ រឿងហ្នឹងទេ ...ចុះថនឯងមានឆ្ងល់ឬទេថា ម៉េចក៏ប្រុសៗខ្លះ មិនយកប្រពន្ធ ?

-ឆ្ងល់ដែរតែមិនសូវចាប់អារម្មណ៍ខ្លាំងដូចករណីស្រីៗឡើយ

-បើចង់ដឹងហើយ... ខ្ញុំអាចប្រាប់បាន... តែវែងឆ្ងាយបន្តិច គេក៏នៅស្ងៀមមួយសន្ទុះ រួចទាញសៀវភៅមួយមកកាន់បើកចុះបើកឡើងមើលបណ្តើរនិយាយបណ្តើរ ៖

-មែន ខ្ញុំស្អប់ប្រុសមែន...ជាតិនេះខ្ញុំប្រហែលស្មាលាហើយ...មានរឿងច្រើនណាស់ ឥឡូវនិយាយតែរឿងធំៗទៅចុះ ថនឯងប្រហែលមិនដឹងទេ ប្រុសៗអាក្រក់ណាស់...មិនបាច់និយាយពីតាខ្ញុំទេ ត្រឹមឪពុកខ្ញុំបានហើយ ។ ម្តាយខ្ញុំជាកូនអ្នកធូរធារមួយដែរ ។ ឪខ្ញុំធ្វើបាបរហូតលែងលះគ្នា... រហូតដល់ស្លាប់យ៉ាងវេទនា។ គាត់ចាញ់ល្បែង ខ្ចីគេខ្ចីឯង ជំពាក់គេរណ្តោកលក់កេរកោះអស់យ៉ាងច្រើន រួចមានប្រពន្ធចុងពីរ ... ចូលចិត្តរករឿងវាយទាត់ធាក់ម្តាយខ្ញុំស្ទើររាល់ពេល ... ទ្រាំមិនបានក៏លែងគ្នាទៅ។ ម្តងនោះ គាត់ឈឺធ្ងន់ម្តាយខ្ញុំអាណិតក៏ទៅព្យាបាល... រួចក៏ជាគ្នាវិញ... ក្រោយមកមិនដឹងទាស់គ្នាយ៉ាងម៉េចគាត់រុញម្តាយខ្ញុំដែលមានទម្ងន់ប្រាំមួយប្រាំពីរខែ... ដួលអុកគូថត្រឡប់ត្រឡិន ប៉ះទូបញ្ឈរក្បែរនោះ ដួលទាំងទូនោះទៀត... ឈាមហូរដូចគេអាររកមាន់ ... ដឹកមកពេទ្យធំ ... ហើយគាត់ក៏ស្លាប់នៅពេលនោះទៅ...។ កាលនោះខ្ញុំនៅរៀនថ្នាក់មធ្យមដ្ឋានទី២ (ថ្នាក់ទី៥) ប្អូនប្រុសខ្ញុំដែលនៅជាមួយខ្ញុំនេះរៀនថ្នាក់បរិវច្ឆណដ្ឋាន (ថ្នាក់ទី២)...មីងខ្ញុំឃើញពិបាកពេកក៏យកទៅនៅជាមួយ...មីងខ្ញុំជាប្អូនម្តាយខ្ញុំបង្កើតគាត់ស្រឡាញ់ម្តាយខ្ញុំណាស់ ប្តីគាត់ធ្វើគយ ផ្ទះគាត់សំបូរសប្បាយណាស់ រីឯឪខ្ញុំ រស់ជាមួយប្រពន្ធចុងគាត់ រហូតគាត់ឈឺធ្ងន់ស្លាប់ទៅ កេរកោះអីៗហិនហោចទាំងអស់។

ខ្ញុំឮរឿងនេះសែនរន្ធត់... សែនអាណិតម្ចាស់សំដី តែគេដូចជានៅធម្មតា។

-អញ្ចឹងយើងមានបងប្អូនរួមឪ រួមម៉ែតែពីរនាក់ទេ មែនទេ ?(ខ្ញុំសួរគេ )

-ហ្នឹងហើយ បើម៉ែខ្ញុំនៅប្រហែលអាចបី ...រួចគេក៏បន្តទៀតថា ៖

-ប្ដីមីងខ្ញុំនៅក្មេង ចូលចិត្តដើរលេងស្ទើររាល់យប់ ឧស្សាហ៍សើចសាសងដាក់ខ្ញុំណាស់ ... ដូចជាគួចប៉ងអ្វីមួយ។ឆ្នាំប្រឡងឌីប្លូមខ្ញុំអាយុប្រហែល១៧ ឬ ១៨ ... ថ្ងៃមួយគាត់និយាយលួងលោមខ្ញុំ ... អ៊ូ ... ថាពីរោះស្ដាប់ ក៏ដូចជាពិបាកស្ដាប់។ ម្ដងនោះ គាត់ប្រុងផ្ដេសផ្ដាស ... តែមីងខ្ញុំដឹងទាន់។ ខ្ញុំក៏ចេញធ្វើគ្រូទៅ ពេលជាប់ឌីប្លូមភ្លាម រួចក៏ខំរៀនខ្លួនឯងបន្ត បន្តរហូតដល់ពេលនេះ តាមសន្ទុះចិត្តដែលចង់ចេះ ...

-សុំសរសើរហើយ ពិសេសសុំចាញ់ផង រឿងនេះ(ខ្ញុំនិយាយកាត់)ចុះកាលរៀនច្បាប់គ្រូស្នាក់នៅឯណា?

-នៅជាមួយម្ដាយមីងម្នាក់ទៀត... គាត់មេម៉ាយប្ដីលែង។ រួចគេបន្តទៀតថាៈ

-នៅរៀនច្បាប់ ខ្ញុំឃើញអស់ហើយ ប្រុសៗជ្រើមដូចត្រីចង្វារ ក្នុងរង្វះទឹក... ខ្លះតាម ខ្លះបោះសំបុត្រ ខ្លះបោះសំដី ... ដូចខ្លួនគេគ្មានបងប្អូនស្រី ឬគ្មានម៉ែបេះបិត ។ ប្អូនខ្ញុំនេះទៀត ពេលវាពេញវ័យ ក៏ផ្ដេសផ្ដាសច្រើនដែរ

-នេះព្រោះគ្នាស្រឡាញ់ តែមិនដឹងធ្វើម៉េចសម ...

-បានហើយ !

-នេះព្រោះគ្នាគ្មានការអប់រំណ៎ា ... ពិសេសកុនសៀវភៅរូបថតបនបារនិងឆាកជីវិតសព្វថ្ងៃទាញគ្នាឱ្យចុះផ្លូវហ្នឹង

-រឿងនេះឯងដែលខ្ញុំគិតមិនអស់មិនហើយ។ ទីបំផុត ខ្ញុំឃើញប្រុសអាក្រក់ក្រៃណាអាក្រក់ ល្មមខ្ញុំឆ្អើមនិងឆ្អែត

-ត្រឹមបីប្អូននាក់យើងភ្ជាប់ទៅទាំងអស់ ដូចជាមិនសម

-មិនមែនតែប៉ុណ្ណឹងទេ មើលត្រឹមពេលនេះកន្លែងនេះឃើញរាប់មិនអស់ទៅហើយ...សុទ្ធតែមាសទឹកដប់ ... ទុកគេសុទ្ធតែជាចំណីខ្លួន ... ជិះជាន់គេតាមទំនើងចិត្ត។សម័យបុរាណម្ចាស់វិមានខ្លះប្រមូលស្រីយកមកកំដរចំណង់ពេញៗវិមាន រួចក្រៀវប្រុសបម្រើទាំងអស់ ... តើវេទនាក្អែកប៉ុនណា? ព្រះបាទព្រហ្មទត្តក្ដោបមួយរាំង គ្រាន់តែកាកីមានក្រៅមួយពីរយកទៅសម្លាប់យ៉ាងវេទនា។ព្រះរាមគ្រាន់តែសង្ស័យបញ្ជោឱ្យសម្លាប់នាងសីតាចោល ... ចំណែកព្រះ-លក្ស្មណ៍ គ្រាន់តែនាងសូរបនខាសុំស្នេហ៍ ក៏ធ្វើ បាបនាងយ៉ាងឃោរឃៅ ។ព្រះចៅស៊ុលតង់ ក្នុងរឿងមួយពាន់មួយយប់ គ្រាន់តែស្រីម្នាក់ក្បត់ បានសម្លាប់ស្រីចោលម្នាក់មួយយប់រាល់ៗយប់...ចនឯងក៏ប្រហែលជាអញ្ចឹងដែរមិនជឿថាអ្នកផ្ទះមានទាក់ទងប្រុសណាម្នាក់លមើល។ តើឯណាទៅភាពស្មើគ្នា ឬសមហេតុសមផល ?

-មិនមែនអញ្ចឹងគ្រប់គ្នាទេ (ខ្ញុំសើចញឹមៗ) ហើយប្រុសបែបហ្នឹងក៏យើងមិនឱ្យតម្លៃដែរ។ ខ្សត់អីប្រុសស្លូតត្រង់ល្អដែលគោរពស្រីដែលស្រឡាញ់ស្រីដែលស្មោះនឹងប្រពន្ធ ដែលអាណិតប្រពន្ធ។ ទុំស៊ូស្លាប់រស់ជាមួយទាវ ... ប៉ូលសុខចិត្តស្លាប់ក្រោយពីវាហ្ស៊ីនីស្លាប់...រឿងមាយាស្រីទោះបីដឹងថាប្រពន្ធផិតក៏ដោយ ប្ដីនៅតែមិនធ្វើបាបនាងជានិច្ច ហើយក្នុងរឿងតំណាលមួយនោះពេលស្ដេចលចិត្តប្ដីឱ្យសម្លាប់ប្រពន្ធ ប្ដីមិនដាច់ចិត្តលើកដាវ ផ្ដាច់ព្រលឹងនាងទេ ... ក្រៅពីនេះ ...

-មានតែក្នុងសៀវភៅទេ (គេនិយាយកាត់)

ខ្ញុំភ្ញាក់ព្រើត ព្រោះប្រុសដែលគេរាប់មុននេះ ក៏នៅតែក្នុងសៀវភៅដែរ។

-ព្រះថៅស៊ុលតង់ (ខ្ញុំឆ្លើយ) មួយវិបដំបូង ធ្វើបាបស្រីមែន តែក្រោយមកដោយសារប្រាជ្ញា នាងសេហេរាហ្សាត ក៏ទទួលស្គាល់ គោរព និងស្រឡាញ់ស្រីលើសដើមផង ដោយបានផ្លាស់គំនិតចាស់ចោលទាំងអស់។ព្រះរាមក្រោយមកក៏ដឹងខ្លួនដែរ...។យើងម៉ែទូទៅលើប្រុសគ្រប់រូបយ៉ាងនេះ ដូចជាមិនសមទេ ... យើងគួររកថា ហេតុអ្វីក៏ប្រុសខ្លះខូច ? រួចខូចនោះកែបានឬទេ?... បើនិយាយពីខូច ស្រីខ្លះក៏ខូចដែរ ... តែគេមិនត្រូវអះអាងដូចព្រះថៅស៊ុលតង់ថា ស្រីៗសុទ្ធតែខូចនោះទេ ...

-កែ ! (គេពោលដោយភ្ញាក់) ... កែយ៉ាងម៉េច ... លោកសង្ឃខ្លះ និងអាចារ្យខ្លះ ក៏មានចុះកាសែតដែរ ... ថនឯង កែអ្នកដែលនៅក្បែរយើងឱ្យឈប់មានប្រពន្ធបីបួនលមើល ... ឱ្យឈប់បោកបំផ្លាញព្រហ្មចារីរបស់ស្រីលមើល ឱ្យឃើញស្រី លែងគិតថាឃើញចំណីលមើល ...

-កែបាន នៅពេលដែលសង្គមមនុស្សរៀបចំស្រួលបួល ... ពេលមានការអប់រំស្រួលបួល ... ហើយនេះជាភារៈយើងស្រាប់ហើយដែលត្រូវកែក្មេងតាំងពីឥឡូវទៅ ...

-រៀបចំស្រួលបួល ! ថនឯងមានដឹងទេថាក្រោយពីចម្បាំងសង្គមមនុស្សនឹងមានបញ្ហាសល់ស្រី ពេលនោះប្រុសៗដែលនៅរស់ រឹតតែឡើងចាងទៅទៀត...

-ស្រេចលើការរៀបចំនិងអប់រំទេ!...ដល់ពេលនោះសឹមគិតទៀត ។ តាមខ្ញុំប៉ាន់ យើងហ្នឹងបែបធ្លាប់មានវិបត្តិអ្វីមួយហើយបានជាដាច់អហង្ការម្លឹងៗ។បើយ៉ាងនេះមែន បើស្អប់ប្រុសខ្មែរ យកប្ដីបរទេសក៏គ្មានទាស់អ្វីដែរ...ដូចប្រុសយើងខ្លះយកប្រពន្ធបារាំងអញ្ចឹងណ៎ា ...

-វិបត្តិ ! ... ប្ដីបារាំង (គេសើចញឹមៗ) ... នារីខ្លះមានវិបត្តិមែន ទើបសម្រេចចិត្តលែងយកប្ដី ឬ ទៅបួសទាំងឈឺចិត្ត...ចំណែកខ្ញុំគ្មានទេ...ខ្ញុំគ្មានគិតប្រុសបារាំង ប្រុសខ្មែរអីទេ ... ប្រុសគឺប្រុសដូចតែគ្នាហ្នឹង ... មានខ្លះបោះពាក្យថា ខ្ញុំអេ ... យីអស្ចារ្យមែន ...

-ក្រែងយើងថាខ្លួនឯងទេដឹង ! (ខ្ញុំញឹមៗ)

-ថនឯងប្រហែលជាដឹងហើយ ប្រុសខ្លះលួចតាំងពីបាយអ្នកជំងឺ ឬបាយអ្នកជាប់ទោសឡើងទៅ ... ប្រុសខ្លះសម្លាប់គេឯង និងទាត់ធាក់គេឯង គ្មានញញើតដៃប៉ុនចុងក្រចកទេ ... ប្រុសខ្លះមួលបង្កាច់គេជាងស្រីទៅទៀត ... ប្រុសខ្លះ ...

-យើងហ្នឹងចេះតែប៉ាតណាប៉ាតណីហើយ ...

-អត់ប៉ាតទេ (គេកាត់) ប្រុសខ្លះទុកប្រពន្ធដូចខ្ញុំកំដរ ខ្លះភរប្រពន្ធរាល់យប់រាល់ថ្ងៃ ... មនុស្សយើងតែភរគេ គឺមើលងាយគេពេញទី ... ខ្លះប្រពន្ធឈឺ គ្មានអើតអីបន្តិច ... ប្រពន្ធស្លាប់មិនទាន់បានប៉ុន្មានថ្ងៃផងបណ្ដើរមួយផ្សេងទៀត ...

-នេះជារឿងប្រុសខ្លះប៉ុណ្ណោះ...ចុះប្រុសដែលល្អមួយគំនរ តាំងពីតូចដល់ធំ តាំងពីអ្នកកាប់គាស់លីសែង ដល់គ្រូពេទ្យ ទស្សនវិទូ អ្នកប្រាជ្ញ អ្នកស្រាវជ្រាវ ...

-មិនតិចទេៗ ... ពេលរៀបចំស្រួលបួល រឹតតែច្រើនទៅទៀត ... ម្យ៉ាងទៀត តាមវិទ្យាសាស្ត្រ យើងនៅម្នាក់ឯងយ៉ាងហ្នឹងអាយុមិនវែងដូចអ្នកមានគ្រួសារទេណ៎ា ...

-ខ្ញុំដឹងហើយ អាយុមិនវែងព្រោះអ្នកលីវទាំងនោះ មានចំណង់កាមក្រាស់... លុះបំពេញមិនគ្រប់ក៏បែកគំនិតប្រព្រឹត្តផ្ដេសផ្ដាស ខ្វល់ចិត្ត កើតទុក្ខ ខូចសរសៃខួរ ជាហេតុនាំឱ្យខ្លួនប្រាណខ្សោយទៅៗ។ មើលមេវត្តខ្លះ ឬមនុស្សខ្លះដែលមិនលង់ ឬមិនអើពើក្នុងផ្លូវកាម គេនៅតែអាយុ ៨០-៩០ ដូចតែគ្នា ... ខ្ញុំ

ភ្ញាក់ព្រឺត ព្រោះមិនស្មានថា គេចេះយល់ច្បាស់យ៉ាងនេះ។ តាមពិត... មែន... បើនរណាមានចំណង់ផ្លូវកាមតិចអ្នកនោះអាចរស់នៅម្នាក់ឯងដោយធ្វើការអ្វីៗផ្សេងៗបានយ៉ាងច្រើន។ខ្ញុំក៏ដេញដោលគេទៀតថា៖

-ចុះមានគិតថាយើងផ្ទុយនឹងធម្មជាតិឬទេ ?

-តើទាស់អីធំដុំ? អ្នកប្រាជ្ញខំផ្ទុយធម្មជាតិមួយគំនរ ... អ្នកស្វែងធម៌អាថ៌ក៏យ៉ាងនេះដែរ ... ថនឯង ប្រុសៗសន្មតថា អត់ខ្ញុំមួយទៅ ចប់ទៅហើយ ...

-សន្មតយ៉ាងម៉េច ... បើនៅជ្រងោរ-ងោរ ... ញញឹមប៉ប្រឹម...។ចុះមាននឹកចង់បានកូនតពូជឬទេ បើយើងរៀនពូកែ និងចេះដឹងច្រើនយ៉ាងហ្នឹង ?

-អ៊ូកូនគេឯទៀតយកទៅណាអស់...ខំបណ្ដុះយ៉ាងណា ឱ្យបានភ្លឺថ្លាគ្រប់គ្នាទៅ វាប្រសើរស្រេចទៅហើយ...ម្យ៉ាងទៀតព្រោះតែរឿងកូននេះឯងទើបប្រុសៗភាគច្រើន ចូលចិត្តជិះជាន់គេគ្មានអាណិតអាសូរ ...

-នៅតែជិះជាន់ៗ... ស្ត្រីក៏មានល្អមានអាក្រក់ ... ប្រុសក៏មានល្អមានអាក្រក់... ខ្យត់អីអ្នកដែលខំស៊ូអត់បាយ អត់ទឹក រងទុក្ខរងទោស ខ្លះស្លាប់ខ្លះរបួសក្នុងគុក ក្នុងនាំង លើលានប្រយុទ្ធ កណ្ដាលវាលកណ្ដាលព្រៃ កណ្ដាលភ្លៀង ឬកណ្ដាលខ្យល់ ... ភាគច្រើនសុទ្ធតែប្រុស ... តើដើម្បីអ្វី ... មិនដើម្បីរកសេចក្ដីល្អទេឬ ... អ្នកទាំងនោះមិនសុទ្ធតែជាអ្នកល្អទេឬ ?

គេនៅស្ងៀម។ ខ្ញុំក៏សួរបន្ថែមបែបលេងៗ :

-ក្រែងយើងខ្លាចពិបាកឆ្លងទន្លេទេដឹង ... ខ្ញុំឮស្រីៗច្រើនណាស់ត្អូញត្អែរដាក់ប្ដីដោយច្រណែនថា ពរពោះពីប្រាំបីទៅប្រាំបួនខែក៏ពិបាកនិងពេលកើតក៏ពិបាក កើតហើយក៏ពិបាកទៀត... ពេលខ្លះឈឺរហូតស្លាប់ផងក៏មាន

-ទេ ... (គេសើចញឹមៗ) ឆ្លងទន្លេជារឿងធម្មតា ... ។ រឿងធំគឺខ្ញុំមិនជឿថា ប្រុសត្រង់ ប្រុសល្អ ប្រុសស្មោះ ប្រុសមិនរំលោភនោះតែម្ដង ... ថនឯងឃើញទេក្របីបាក្នុងរឿងរាមកេរ្តិ៍សម្លាប់កូនឈ្មោលៗទាំងអស់ ព្រោះអ្វី ?

-យើងចេះតែម៉ែទូទៅមុនឃើញសព្វគ្រប់ មុនដឹងសព្វគ្រប់ ឬមុនថ្លឹងសព្វគ្រប់ ទើបមានចិត្តយ៉ាងនេះ។ តាមពិតមិនខ្វះទេប្រុសល្អ ... មិត្តភក្ដិយើងក៏ល្អច្រើនដែរ... ម្នាក់នោះក៏ល្អណាស់ដែរ... ហើយទម្រាំស្រុកទេសរៀបចំស្រួលបួលរឹតតែល្អច្រើនឡើងថែមទៀត។

-ម្នាក់ណា៎... ខ្ញុំដឹងហើយ... ឥឡូវចាំស្រុករៀបចំស្រួលបួល សឹមគិតទៀត ... ពេលនេះនិយាយពីសូក្រាត ប្លាតុង ដេកាត កាន្ត និងទ្រឹស្ដីទស្សនវិជ្ជាផ្សេងៗ ឬធំៗ ឱ្យស្ដាប់ម្ដង... ព្រោះយើងបានមើលសៀវភៅច្រើន ...

-ទ្រឹស្ដីទស្សនវិជ្ជាធំមួយ គឺយើងហ្នឹង មិនគួរនៅម្នាក់ឯងណា៎ ជឿឬទេ បើមិនជឿ រឿងអីៗទៀតខ្ញុំពន្យល់ទៅក៏មិនយល់ដែរ។

រំពេចនោះ គេប្រែទឹកមុខ... រួចពោលតិចៗដោយសំលេងអួលៗថា « ថនឯង ប្រហែលមិនជឿទេ ឬមិនដឹងទេ... ថាខ្ញុំសព្វថ្ងៃជាមនុស្សឈឺ... » ។

លំនឹកពីអតីត ២០២៣
បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ថុង



ប្រសាទនាងខ្មៅ ស្ថិតនៅឃុំទៀង ស្រុកសំរោង ខេត្តតាកែវ

